www.khmerpostusa.com
សារព័ត៌មាន ខ្មែរផុស ស.រ.អា
# KhmerPost USA
Lowell - Lynn - Revere - MA * Providence - Cranston - RI

Free Copies
Vol. 13. Issue #305
Nov 27Th, 2020
Office: 978-677-7163
Direct: 978-656-8141
Email:Khmerpostusa@gmail.com

## ព័ត៌មានសំខាន់ៗខាងក្នុង...

កម្ពុជាគួរតែបារម្ភជាមួយប្រធានាធិបតីបាយដិន សូមអាននៅទំព័រទី ០៤



បុណ្យឯករាជ្យ៩វិច្ឆិកា ឆ្នាំ២០២០ នៅភ្នំពេញ សូមអាននៅទំព័រទី ០៥



គណបក្សសាធារណរដ្ឋ និងគណបក្សប្រជាធិបតេយ្យ... សូមអាននៅទំព័រទី ០៧




អាមេរិកកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ សូមអាននៅទំព័រទី ១១



## សេង ធារី មេធាវីសិទ្ធិមនុស្សសញ្ជាតិ ខ្មែរ-អាមេរិក និងមនុស្ស៦៧នាក់ផ្សេងទៀត ប្រឈមការកាត់ទោសពីបទក្បត់ជាតិ នៅប្រទេសកម្ពុជាចំថ្ងៃទិវា Thanksgiving Day

ថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២០

ដោយ ពិន សុបិនៈ

ក្នុងពេលវឹកវរនៃការបោះឆ្នោតអាមេរិក នៅថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២០ អាជ្ញាធរកម្ពុជាបានចេញបទបញ្ជារឱ្យសកម្មជននយោបាយចំនួន៦៧នាក់ ឡើងតុលាការពីបទក្បត់ជាតិ នៅថ្ងៃនេះ នៅម៉ោង៨ល្ងាច ម៉ោងនៅអាមេរិក ឬត្រូវនឹងថ្ងៃព្រហស្បតិ៍ ម៉ោង៨ព្រឹកចំថ្ងៃ Thanksgiving Day នៅប្រទេសកម្ពុជា ។ អ្នកទាំងនោះភាគច្រើន គឺជាអតីតសមាជិកគណៈបក្សសង្គ្រោះជាតិ (CNRP)



His Excellency Thach Setha



សេង ធារី ផ្តល់បទសម្ភាសន៍ដល់អ្នកសារព័ត៌មាន ក្រោយពេលចូលតុលាការក្រុងភ្នំពេញ នៅព្រឹកនេះ ២៦,១១,២០២០

ប៉ុន្តែក៏មាន សេង ធារី ផងដែរដែលជាមេធាវីសិទ្ធិមនុស្ស សញ្ជាតិខ្មែរ-អាមេរិក ដែលគេស្គាល់ថាជាសកម្មជនសិទ្ធិមនុស្សមិនសំចៃមាត់ម្នាក់ប្រឆាំងនាយករដ្ឋមន្ត្រី ហ៊ុន សែន និងរដ្ឋាភិបាលរបស់លោក ។

សិទ្ធិមនុស្សនៅកម្ពុជាកាន់តែអាក្រក់យ៉ាងលឿនក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ក្រោយការរំលាយចោលគណៈបក្សប្រឆាំង (CNRP) ដែលមានសមាជិកសភាជាប់ឆ្នោតចំនួន ៥៥ រូប ។ ការបោះឆ្នោតក្នុងឆ្នាំ២០១៨ គណៈបក្សប្រជាជនកម្ពុជា(CPP) បានក្លាយជាបក្សកាន់អំណាចតែមួយក្នុងប្រទេស ។

ចាប់តាំងពីពេលនោះមករបបនេះ បានបិទចោលសេរីភាពសារព័ត៌មាន ដូចជា កាសែត ឌឹ ខាមបូឌា ដេលី (Cambodia Daily) វិទ្យុអាស៊ីសេរី (RFA) និងវិទ្យុសម្លេងប្រជាធិបតេយ្យ (VoD) បន្ទាប់មកទៀត បានចាប់អ្នកកាសែត សកម្មជនសិទ្ធិមនុស្សដោយសារតែការធ្វើ **តទៅទំព័រទី ០៨**

## A Cambodian American Civil Rights Lawyer Theary C. Seng and 67 others Face Trials for Treason in Cambodia on Thanksgiving Day

By Soben Pin

Two prominent figures charged for treason are including Theary C. Seng, a Cambodian American civil rights lawyer and His Excellency Thach Setha, former Cambodia Parliamentary Senator –a Khmer Krom native from Preah Trapeang Province, Kampuchea Krom.

New record found the number people have been summoned to court for treason as many as 140 people, who mostly are the CNRP members. Two prominent figures charged for treason are including Theary C. Seng, a Cambodian American civil rights lawyer and His Excellency Thach Setha, former Cambodia Parliamentary Senator (1996-2015) who is from Preah Trapeang Province, Kampuchea Krom. Present today under Vietnam, known as Tra Vinh Province. Over 34 people appeared in court today and they were divided into two groups for their trial dates. Theary's court date has moved to January 14, 2021. H.E. Thach Setha's court date moved to March 4th, 2021.

In the midst of a U.S. election chaos, on November 4th, 2020, the Cambodia authority ordered 67 political activists to stand trial for treason today at 8 pm — U.S. Eastern time, or Thursday 8 am Thanksgiving Day in Cambodia. This includes **Continued to Page 08**



មេធាវី លុយ ហាស្កែល LAW OFFICE OF LOUIS S. HASKELL

សេវាកម្មជាទីគាប់ចិត្តចាប់តាំងពីឆ្នាំ 1987

Excellent Service Since 1987

គ្រោះថ្នាក់ចរាចររថយន្តតូច, រថយន្តធំ និងម៉ូតូ • អន្តោប្រវេសន៍

ពន្ធ • ការក្ស័យធន • គ្រោះថ្នាក់រអិលដួល • ឆ្កែខាំ

ដំណោះស្រាយ និងការពារបញ្ហាពន្ធដា

សូមអរគុណចំពោះការបន្តទុកចិត្តរបស់លោកអ្នកមកលើការិយាល័យមេធាវីយើងខ្ញុំ ក្នុងការដោះស្រាយបញ្ហាផ្នែកច្បាប់ និងពន្ធដារជូនលោកអ្នក ។ យើងខ្ញុំរំពឹងថា នឹងបានបម្រើលោកអ្នកយ៉ាងល្អនាពេលអនាគត។

បុគ្គលិកយើងខ្ញុំនិយាយភាសាខ្មែរ

Auto, Truck and Motorcycle Accidents
Immigration • Tax • Bankruptcy
Slip & Fall • Dog Bite
Tax Resolution & Defense

Thank you for your continued confidence
In our office to handle your legal and tax matters.
We look forward to serving you well into the future.

LAW OFFICE OF LOUIS S. HASKELL • 16 PINE STREET • LOWELL, MA • (978) 459-8359

16 Pine Street • Lowell, MA • 978-459-8359 • www.attorneyhaskell.com

# មណ្ឌលពិនិត្យសុខភាពឡូវែល

# Lowell Primary Care Center

លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, **M.D.** លោក ឆាន់ ទូច , **C.N.P.**

**Sokharith Mey, M.D.** **Chhan Touch, C.N.P.**





ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី

**Now Accepting New Patients**

ជំងឺទូទៅ សុខភាពផ្លូវចិត្ត

***Family Medicine*** & ***Behavioral Health***

អាស័យដ្ឋាន

**1075 Westford Street, Unit 204 • Lowell, MA 01851 • (978) 455-7992**

ទទួលយកម៉ាសហេល្ត មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

We Accept MassHealth, Medicare and Other Health Insurances
Our Staff Speaks Khmer • Plenty of Free Parking


បើកទទួលការចុះឈ្មោះ បញ្ចប់នៅ
ថ្ងៃទី23 ខែមករា
MASSACHUSETTS
HEALTH
CONNECTOR
the right place for the right plan
ទទួលយកការធានារ៉ាប់រង
នៅតែស្ថិតក្រោមការធានា
រ៉ាប់រង
យើងទាំងអស់គ្នាមានតួនាទីធ្វើឱ្យសហគមន៍
របស់យើងមានសុខភាពល្អ
ជាមួយនឹងទីភ្នាក់ងារ Health Connector អ្នកអាចរកបានការធានារ៉ាប់រងគុណភាព
ខ្ពស់ បូករួមនឹងគម្រោងចំណាយទាប ឬគ្មានការចំណាយតែម្តង នៅទីកន្លែងតែមួយ។
គ្រប់គម្រោងទាំងអស់តាមរយៈទីភ្នាក់ងារ Health Connector ធានារ៉ាប់រងទៅលើអត្ថ
ប្រយោជន៍សំខាន់ៗ ដូចជា៖ ការទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ សេវាកម្ម
សង្គ្រោះបន្ទាន់ ការស្នាក់នៅមន្ទីរពេទ្យ ការថែទាំពេលមានផ្ទៃពោះ និងទារកទើប
កើត សេវាកម្មស្ពានីតិសម្បទា ការពារ និងសុខុមាលភាព សេវាកម្ម
មន្ទីរពិសោធន៍ សុខភាពផ្លូវចិត្ត និងការញៀនថ្នាំ ហើយជាច្រើនទៀត។
www.MAhealthconnector.org
1-877-623-6765 | TTY 1-877-623-7773
ត្រូវការជំនួយក្នុងការចុះឈ្មោះមែនទេ? សូមទូរស័ព្ទដើម្បីណាត់ជួបជាមួយមជ្ឈមណ្ឌល
នៅក្នុងតំបន់របស់អ្នក
Lynn Community Health Center
781-581-3900
269 Union St, Lynn, MA 01901
Boston Public Health Commission
1800-847-0710 | 617-534-5050
1010 Massachusetts Ave, Boston, MA 02118
Greater Lawrence Community Action Council
978-620-4784
305 Essex St, Lawrence, MA 01840

# កម្ពុជា គួរតែបារម្ភជាមួយប្រធានាធិបតី បាយដិន

## រដ្ឋបាលបាយដិន ប្រហែលជានឹងរក្សាគោលនយោបាយ "ចូលរួម" ជាមួយកម្ពុជា តែជាមួយរូងថ្ម

ដោយៈ ដេវីដ ហាត់ (DAVID HUTT)
១២ វិច្ឆិកា ២០២០

ការវាយកំទេចចោលទីតាំងមួយទៀត ដែលបានកសាងឡើងដោយអាមេរិកនៅឯមូលដ្ឋានទ័ពជើងទឹករាម គឺជាការយកមេដៃចាក់ភ្នែករដ្ឋាភិបាលអាមេរិកកាន់តែខ្លាំងជាសញ្ញាមួយ ដែលក្រុងភ្នំពេញកំពុងតែក្រអឺតក្រទម មិនអើពើការរំញោចអាមេរិកឬនៅតែមិនយល់ហានិភ័យ។

ការកំទេចចោលទីតាំងមួយទៀតដែលបានកសាងដោយអាមេរិក នៅមូលដ្ឋានដដែលក្នុងខែកញ្ញា បានធ្វើឱ្យមន្ទីរប៉ង់តាហ្គូនសំដែងការព្រួយបារម្ភម្តងទៀតថា រដ្ឋាភិបាលកម្ពុជា នឹងអនុញ្ញាតឱ្យកងទ័ពចិនឈរជើងនៅលើទឹកដីខ្លួន ជាការព្រួយបារម្ភធំមួយដល់អាមេរិក និងការអភិវឌ្ឍ ដែលនឹងរុញកម្ពុជាឱ្យនៅពីមុខ និងនៅចំកណ្តាលនៃការប្រជែងរវាងអាមេរិក-ចិន។ ក្រុងភ្នំពេញទាមទារកំទេចចោលទីតាំងទាំងនេះ គឺធ្វើផ្លូវសម្រាប់ការអភិវឌ្ឍថ្មី "ការបកស្រាយមួយមិនសមទាល់តែសោះ ទីតាំងដែលបានកសាងដោយអាមេរិក រយៈពេលទើបតែបីឆ្នាំមុនបែរជាត្រូវបានកំទេចចោលទៅវិញ ហើយទីតាំងនោះ មិនធ្វើឡើងសម្រាប់យោធាប្រើប្រាស់ជាមួយចិននោះទេ។ ច្បាស់ក្រឡែតរដ្ឋាភិបាលកម្ពុជាមានផលប្រយោជន៍តិចតួចក្នុងការបន្ថយការព្រួយបារម្ភ អាមេរិក នៅលើតួនាទីយោធាចិនក្នុងប្រទេស។ តាមពិតការសម្រេចចិត្តចុងក្រោយបង្ហាញនូវកង្វះការយកចិត្តទុកដាក់ខ្លាំង (មានទំនុកចិត្តហួសហេតុ) លើទង្វើរបស់ខ្លួន បើទោះបីក្រុងវ៉ាស៊ីនតុន យល់បែបណាក៏ដោយ។

អ្នកខ្លះនិយាយថា ក្រុងភ្នំពេញស៊ប់នឹងជំនឿដែលអាមេរិកនឹងមិនដាក់ទណ្ឌកម្មធំដុំណាមួយប្រឆាំងនឹងខ្លួនឡើយ ព្រោះតែទ្រឹស្តីថា ការធ្វើអញ្ចឹង នឹងរឹតតែរុញកម្ពុជាខិតចូលកាន់តែជិតគន្លងចិន ជារឿងមួយដែលអាមេរិកចង់ជៀសវាង។



កងទ័ពជើងទឹកកម្ពុជា នៅលើនាវាចតនៅកំពង់ផែសមុទ្រមូលដ្ឋានទ័ពជើងទឹករាមក្នុងខេត្តព្រះសីហនុ ថ្ងៃទី២៦ កក្កដា ឆ្នាំ២០១៩ អំឡុងពេលដំណើរទស្សនៈកិច្ចអ្នកសារព័ត៌មានរៀបចំដោយរដ្ឋាភិបាល។ រូបថតៈ AFP , តាំង ជិនសុធី

អ្នកវិភាគលោក ប្រាដលី មឺក (Bradley Murg) ហៅរឿងនេះថា "ជាការឈ្លោះគ្មានការលើកទឹកចិត្ត" នៅក្នុងបទនិពន្ធកាលពីខែមុនសរសេរថា "ហានិភ័យទំនាក់ទំនងក្លាយជាជាប់សោរ ក្រោមកងល្បួសបន្ទាជាមួយការមិនលើកទឹកចិត្តកម្ពុជា ដែលកំពុងតស៊ូមតិ និងបង្ហាញភាពត្រឹមត្រូវឆ្លើយតបដឹលំបាកមួយចំពោះទង្វើអាមេរិក ដោយមិនខ្វល់ភាពស្មុគស្មាញ" រវាងអាមេរិក-កម្ពុជា។

ក្រុងភ្នំពេញ គួរតែប្រយ័ត្នប្រយែង។ នៅពេលអ្នកធ្វើច្បាប់អាមេរិកភាគច្រើន ប្តេជ្ញាចិត្តមានទំនាក់ទំនងជាមួយកម្ពុជា មានខ្លះ ខ្ញុំបានឮអ្នកដែលគិតថាប្រទេសបាន "បាត់បង់ទៅចិនរួចហើយ" ដូច្នេះការទំនាក់ទំនងណាមួយគឺនាំឱ្យខូចប្រយោជន៍ជាការខ្ជះខ្ជាយថវិកាអាមេរិក ដែលបានផលតែលើគណៈបក្សកាន់អំណាចកម្ពុជា ហើយមិនជាអ្នកគាំទ្រ។ ក្តីសង្ឃឹមនៃមតិនេះ មិនលើសលុបទេ ប៉ុន្តែក្រុងភ្នំពេញ កំពុងតែធ្វើតិចតួចបំបាត់វា ជាពិសេសក្នុងពេលផ្លាស់ប្តូរអំណាចទៅក្រុងវ៉ាស៊ីនតុន។

តាមពិត ពេលវេលានៃការកំទេចចោលលើកទីពីរ នៅឯមូលដ្ឋានកងទ័ពជើងទឹករាម គឺជាការសង្ស័យកើតឡើងខណៈពេលក្រុងវ៉ាស៊ីនតុន ថ្លែសប្រហែស។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏នៅស្ងៀមអំពីជ័យជំនះលោក ចូ បាយដិន មិនទាន់ផ្តល់ការអបអរសាទរនៅឡើយ។

ពីមុនគាត់ គឺជាអ្នកគាំទ្រ ដូណាល់ ត្រាំ ពីដើមទីផ្តល់សម្លេងគាំទ្រគាត់មុនការបោះឆ្នោតឆ្នាំ២០១៦ "ទោះបីជាការគាំទ្រនោះមានអត្ថន័យតិចតួច នៅពេលដែលក្រុងភ្នំពេញ "ផ្អាក" សមយុទ្ធយោធារួមគ្នាជាប្រវត្តិសាស្រ្តជាមួយអាមេរិក ប៉ុន្មានថ្ងៃ មុនពិធីឡើងកាន់តំណែងលោក ត្រាំក្នុងខែមករា ឆ្នាំ២០១៧ និងក្រោយមក បានចាប់ផ្តើមលំហាត់ជាមួយយោធាចិន។

អាមេរិកបានប្រតិកម្មយ៉ាងខ្លាំង ក្រោយពេលគណៈបក្សប្រឆាំងដ៏ធំនៃប្រទេសកម្ពុជា គឺគណៈបក្សសង្គ្រោះជាតិ (CNRP) ត្រូវបានរំលាយដោយបង្ខំ ហើយមេដឹកនាំបក្សត្រូវបានចាប់ខ្លួនពីបទក្បត់ជាតិ ចុងឆ្នាំ២០១៧ ពីបទធ្វើរដ្ឋប្រហារគាំទ្រដោយអាមេរិក គឺជាការយកមេដៃចាក់ភ្នែកក្រុងវ៉ាស៊ីនតុន។

ក្រុងវ៉ាស៊ីនតុន បានពិពណ៌នាការបោះឆ្នោតសកលឆ្នាំ២០១៨ ថាជា "ការបោះឆ្នោតមិនសេរី និងត្រឹមត្រូវមិនតំណាងឱ្យឆន្ទៈពលរដ្ឋកម្ពុជា"។

ក្រោយមកជំនួយខ្លះត្រូវបានកាត់។ មេបញ្ជាការកងអង្គរក្សលោក ហ៊ុន សែន ត្រូវបានទទួលទណ្ឌកម្មនៅឆ្នាំនោះ ដោយសារតែតួនាទីគាត់នៅក្នុងអំពើរំលោភសិទ្ធិមនុស្សជាប្រវត្តិសាស្រ្ត។ អតីតមេបញ្ជាការយោធា និងជាសេដ្ឋីមានទំនាក់ទំនងនឹងបក្សកាន់អំណាចត្រូវបានរងទណ្ឌកម្មនៅក្នុងឆ្នាំនេះ ប៉ុន្តែមិនពាក់ព័ន្ធនឹងបញ្ហានយោបាយទេ។

ជាសង្ខេបគ្មានការដាក់ទណ្ឌកម្មមកលើលោកហ៊ុនសែនឬគ្រួសារគាត់និងមន្ត្រីជាន់ខ្ពស់ពាក់ព័ន្ធក្នុងការបង្កើតរដ្ឋមានបក្សតែមួយទេ។ ការពិតក្រោយពាក់កណ្តាលឆ្នាំ២០១៩ អាមេរិកបានព្យាយាមខិតចូលជិតជាមួយក្រុងភ្នំពេញ អស់រយៈពេលជាច្រើនខែ និងមានលិខិតចិត្តសប្បុរសបានផ្ញើពី ត្រាំ ទៅ ហ៊ុន សែន កាលពីឆ្នាំមុន។

តើទំនាក់ទំនងអាមេរិក-កម្ពុជា នឹងនៅបន្តអស្ថេរភាព និងមានលក្ខណៈបិទ-បើកទៀតដែរឬទេ? លោក បាយដិន ត្រូវបានគេរំពឹងថាពិតជាយកចិត្តទុកដាក់កាន់តែខ្លាំងលើសិទ្ធិមនុស្សជាងលោកត្រាំ។ "សិទ្ធិមនុស្សនឹងជាស្នូលនៃគោលនយោបាយការបរទេសអាមេរិក" គាត់បានប្រកាសអំឡុងពេលយុទ្ធនាការ។ តើមានសណ្តាប់ធ្នាប់ឡើងវិញនៃគោលនយោបាយការបរទេសដឹកនាំដោយគុណតម្លៃអាមេរិកដែលកំពុងរងចាំត្រូវបានគេមើលឃើញឬទេ? បុគ្គលនៅជុំវិញលោក បាយដិន ពិតជាជម្រុញឱ្យមានវា។

តទៅទំព័រទី ០៦




"អ្នកដឹងឬទេ?"

# បុណ្យឯករាជ្យ៩វិច្ឆិកាឆ្នាំ២០២០ នៅភ្នំពេញ

ដោយ ពិន សំខុន - ៩វិច្ឆិការ២០១០

រដ្ឋាភិបាលខ្មែរបានប្រារព្ធខួបទី៦៧ឆ្នាំ នៃឯករាជ្យកម្ពុជានៅវិមានឯករាជ្យនាទីក្រុងភ្នំពេញ ដែលទទួលបានពីប្រទេសបារាំង កាលពីថ្ងៃទី ៩វិច្ឆិកា ១៩៥៤ -បារាំងបានគ្រប់គ្រងអនានិគមនៅប្រទេសកម្ពុជាចំនួន១០០ឆ្នាំ ។បានឯករាជ្យពីបារាំងមែនហើយ តែប្រទេសខ្មែរ នៅតែទទួលការទិទៀនថា"តែងតែនៅបំរើផលប្រយោជន៏ប្រទេសចិនប្រជាមានិត នឹងនៅក្រោមការឈ្លានពានបូរណភាពពីវៀតណាម" ជាបន្តបន្ទាប់រហូតមក ។ តើបុណ្យឯករាជ្យខ្មែរឆ្នាំ២០២០នេះ មានន័យយ៉ាងណា?

**កម្ពុជានៅក្រោមអនាព្យាបាលបារាំង**

ប្រទេសកម្ពុជាបានចុះខ្សោយ តាំងតែពីសតវត្សទី១៤ បន្ទាប់ពីរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ជាស្ដេចកាន់ព្រះពុទ្ធសាសនាមហាយានគ្រប់គ្រងដែនដីមហាចក្រកម្ពុជាដែលមានព្រំប្រទល់ជាមួយភូមានឹងចិន នាភាគខាងជើង ខាងត្បូងទល់នឹងសមុទ្រចិន, ជាស្ដេចដែលបានសង់ប្រាសាទបាយ័ននឹងប្រាសាទឯទៀតជាច្រើន ,ប៉ុន្តែបន្ទាប់ពីចូលទីវង្គត់ទៅស្ដេចគ្រងរាជ្យបន្តជាស្ដេចកាន់សាសនាព្រហ្មញ្ញ សាសនា បន្តបន្ទាប់មិនចេះការពារទឹកដីមហាសាលធំល្វឹងល្វើយទេ ធ្វើឱ្យថៃ-ឡាវ-ជ្វា-វៀតណាម បះបោរ វាយគ្នាពង្រីកយកទឹកដីចេញពីមហានគរខ្មែរបង្កើតបានជាស្យាម ឡាវនឹងវៀតណាម, រលាយទាំង "ប្រទេសជ្វា ឬចម្ប៉ា"បាត់ទៅ, ជិតរលាយទាំងកម្ពុជាថែមទៀត ។ឆ្នាំ១៦២៣ រជ្ជកាលស្ដេចជ័យ





ជេដ្ឋា( ការជាមួយកូនស្ដេចយួន)ខ្មែរច្បាំងចាញ់សៀមនឹងទៅពឹងយួនឱ្យជួយច្បាំងនឹងស្យាម-បន្ទាប់ពីច្បាំងរួច យួនក៏បានសុំដីនៅ"ព្រៃគរ" ឱ្យជនជាតិគេរស់នៅផ្នែកខាងកើត។ ចម្បាំងដណ្ដើមទឹកដីខ្មែរបន្តបន្ទាប់, នៅឆ្នាំ១៧៦៧ ដោយស្ដេចឧទ្ទ័យទៅពឹងយួន ដើម្បីបង្រ្កាបស្ដេចអង្គនុនកាពារដោយស្យាម, បុត្រាស្ដេចទាំង២នោះច្បាំងបន្តទៅទៀតដោយទៅពឹងពាក់ប្រទេសជិតខាងទាំង២ទៀត...រហូតមកដល់ស្ដេចអង្គអេង រួចចុងបញ្ចប់ ស្ដេចអង្គចន្ទទី២ ក្លាយជាស្ដេចដែលរងគ្រោះ9សោយរាជ្យនៅអាយុ៥ឆ្នាំ -ចំណុះស្យាមផងនឹងយួនផង ដោយសារប្រទេសសៀមនឹងយួន បានត្រូវរ៉ូវគ្នាចែកដីខ្មែរដែលគេបានកាន់កាប់ហើយ ។ នៅឯឈូងសមុទ្រ ដែនដីសណ្ដរទាំងអស់, បានត្រូវស្ដេចស្រីអង្គម៉ី ដែលនៅជាប់ឃុំឃាំងឯទីនោះ ក៏បានចុះហត្ថលេខាប្រគល់ដែនដី ដែលបានក្លាយជា"កូជិនស៊ិន Co-chinchine"របស់វៀតណាមនៅឆ្នាំ១៨៤១ យកឆ្នេរសមុទ្រខ្មែរនឹងកោះទៅអស់ ។

បន្តិចក្រោយមកទ្រាំមិនបានប្រជារាស្ត្រខ្មែរកំព្រាបានបះបោរវាយទាហ៊ានស្យាមនឹងយួននៅច្រើនទីតាំង ដើម្បីទាមទារឱ្យប្រគល់ស្ដេចគេមកគ្រប់គ្រងរាជ្យនៅកម្ពុជាវិញ។ ក្រុងអាយុធ្យាបានយល់ព្រមបញ្ជូនព្រះរាជបុត្រាព្រះនាម អង្គឌួង ឱ្យមក"គ្រងរាជ្យជាប្រទេសចំណុះ" ហើយបញ្ជូនសួយសារអាករទៅថ្វាយស្ដេចក្រុងអាយុធ្យា ជារៀងរាល់ឆ្នាំ នឹងមានបញ្ជូនពលទាហ៊ានទៅច្បាំងជាមួយទ័ពស្យាមនៅពេលគេត្រូវការទៀត ។

ជាស្ដេចក្រុងកម្ពុជា ហើយមិនចេះច្បាំងមែន តែបានរៀនសូត្របានជ្រៅជ្រះ, ព្រះបាទអង្គឌួងតែងតែនាំសួយសារអាករទៅថ្វាយស្ដេចស្យាម បញ្ជូនទាហ៊ានឱ្យទៅធ្វើសង្រ្គាមជាមួយស្យាម នៅក្រៅប្រទេសធ្វើឱ្យប្រទេសខ្មែរបាន"សុខសន្តិភាព"មួយរយៈ ដែលអាចបង្កើតសាលាឱ្យកូនចៅខ្មែររៀនសូត្រ ពាសពេញប្រទេសបានធ្វើជំនួញជាមួយចិននឹងឥណ្ឌា។ នៅក្នុងពេលចំណុះស្យាមនោះ **តទៅទំព័រទី ១២**






តមកពីទំព័រទី ០៤

# កម្ពុជា គួរតែបារម្ភជាមួយប្រធានាធិបតី...

ព្រឹទ្ធសភាអាមេរិកលោក គ្រីស យូន (Chris Coons) ជាអ្នកសហការកសាងដើមដំបូង នៃច្បាប់ពាណិជ្ជកម្មឆ្នាំ២០១៩ បានគំរាមកាត់ការអនុគ្រោះពាណិជ្ជកម្មកម្ពុជា ជាបេក្ខជនមានសក្តានុពលម្នាក់សម្រាប់តំណែងរដ្ឋមន្ត្រីក្រសួងការបរទេស ហើយប្រសិនគាត់មិនមិនទទួលបានតំណែងនេះក្តី ក៏គាត់នៅជិតដិតជាមួយបាយដិន គាត់កាន់កៅអីអតីតព្រឹទ្ធសភា នៅរដ្ឋ ឌីឡាវ៉ា ១ឌុលើការចេ។

លោក យូន បាននិយាយក្នុងខែមករា ឆ្នាំ២០១៩ថា "ប្រទេសដែលមើលស្រាលលទ្ធិប្រជាធិបតេយ្យ ព្រងើយកន្តើយស្តង់ដារការងារ មិនគោរពសិទ្ធិមនុស្ស និងបរាជ័យក្នុងការការពារកម្មសិទ្ធិបញ្ញា ត្រូវតែមិនអាចទទួលបានការអនុគ្រោះពាណិជ្ជកម្មពិសេសឡើយ។ អំឡុងពេល ៣៤ឆ្នាំក្នុងអំណាច ហ៊ុន សែន បានបង្ហាញការមាក់ងាយមកលើនីតិរដ្ឋ និងសេរីភាពជាមូលដ្ឋាននៅកម្ពុជា"។

គ្មានការសង្ស័យទេ ក្រុងភ្នំពេញសង្ឃឹមថា នរណាម្នាក់ផ្សេងទៀត ប្រហែលជាលោកស្រី ស៊ូហ្សាន រ៉ាយ (Susan Rice) គឺជាបេក្ខជនជាក់ស្តែងម្នាក់ទៀតនឹងបានតួនាទីជារដ្ឋមន្ត្រីក្រសួងការបរទេស។

ច្បាប់លទ្ធិប្រជាធិបតេយ្យកម្ពុជា ឆ្នាំ២០១៩ នឹងត្រូវបានស្នើទៅប្រធានាធបតីអាមេរិកឱ្យដាក់ទណ្ឌកម្មលើបុគ្គល ដែលទទួលខុសត្រូវលើទង្វើមើលស្រាលប្រជាធិបតេយ្យនៅកម្ពុជាបានឆ្លងសភារួចហើយឆ្នាំមុន ប៉ុន្តែមកទើនៅព្រឹទ្ធសភា។

ប៉ុន្តែអ្នកជ្រោមជ្រែងជាច្រើន រួមមានអ្នកប្រជាធិបតេយ្យ លោកអាឡាន់ ឡូវិនថល (Alan Lowenthal) និងលោក ប្រាដ ស៊ឺមេន (Brad Sherman) បានឈ្នះឆ្នោតម្តងទៀតកាលពីសប្តាហ៍មុន។អាចថា អ្នកទាំងពីរនឹងធ្វើឱ្យច្បាប់ទាំងនេះត្រឡប់ទៅសភាវិញ នៅឆ្នាំក្រោយ ជាហានិភ័យចំពោះកម្ពុជា ក្នុងគម្រោងពាណិជ្ជកម្មប្រព័ន្ធអនុគ្រោះទូទៅ (GSP) របស់អាមេរិក និងនាំទៅរកសក្តានុពលដាក់ពន្ធលើទំនិញកម្ពុជា។

(នេះនឹងធ្វើដូចគ្នាទៅនឹងការដកភាគខ្លះរបស់សហគមន៍អ៊ឺរ៉ុបលើការអនុគ្រោះពាណិជ្ជកម្មនៅឆ្នាំនេះ)។

ការពិតហាក់ដូចជានៅមានការគាំទ្រទ្វេភាគីសម្រាប់ច្បាប់ទាំងនេះ និងមានរដ្ឋបាលដែលទទួលយកកាន់តែច្រើន ដើម្បីងើបឈរឡើងសម្រាប់លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ពួកគេអាចស្វែងរកការគាំទ្របានពីខាងផ្នែកប្រតិបត្តិ។

ច្បាស់ណាស់ ការគិតរបស់អាមេរិកមកលើចិនមានការបែងចែក។ នៅម្ខាងមានមនុស្សច្រើននៅក្នុងសភាដែលចង់ដាក់ទណ្ឌកម្មលើរបបក្រុងភ្នំពេញ។ ម្ខាងទៀត មានការព្រួយបារម្ភអំពីអាណានិគមចិន នៅក្នុងតំបន់ និងកំពុងដាក់ទណ្ឌកម្មធ្វើឱ្យក្រុងប៉េកាំង អាចកាន់តែជិតចាប់បានកម្ពុជា។

ក្រោម ត្រាំ ក្រោយមកបានចាប់យកអាទិភាព។ ប៉ុន្តែប្រសិនបើ បាយដិន ត្រជាក់ជាមួយការប្រជែងអាមេរិក-ចិន (អ្នកវិភាគជាច្រើនគិតថា គាត់នឹងមិនត្រជាក់) និងផ្តោតឡើងវិញលើរបៀបវារៈសិទ្ធិមនុស្សអាមេរិកទីក្រុងភ្នំពេញអាចឈឺចាប់។

ការពិត ទីប្រឹក្សាលោក បាយដិន និងទំនងជាសមាជិកខុទ្ទការល័យផង បានពន្លឺសម្លេងខ្លាំងៗលើចិន។ លោកម៉ៃយល ហ្វ៊ឺណូយ (Michele Flournoy) ទំនងជាលោក បាយដិន ជ្រើសរើសធ្វើជារដ្ឋមន្ត្រីការពារជាតិ បានបំភែនៅក្នុងកិច្ចការបរទេសក្នុងឆ្នាំនេះថា ប្រសិនបើអាមេរិកអាច "គំរាមពន្លិចទូក នាវាមុជទឹក និងកប៉ាល់ដឹកទំនិញយោធាចិនទាំងអស់ក្នុងសមុទ្រចិនខាងត្បូងបាន ក្នុងរយៈពេល៧២ម៉ោងមែន" វាអាចការពារមិនឱ្យក្រុងប៉េកាំងយកតំបន់បាន។

ទីប្រឹក្សាលោកបាយដិន ក៏នៅតែអំពាវនាវឱ្យមានការប្រជែងជានិរន្តជាមួយចិន ដែលមិនសូវបានផលជាង ត្រាំ។ តាមរយៈ "យុទ្ធវិធីពឹងផ្អែកពីសម្ព័ន្ធមិត្តការដាក់ទណ្ឌកម្ម និងច្បាប់ផ្សេងទៀត ឥរិយាបថក្រុងប៉េកាំងនឹងចេញរូបរាង" កាសែត ឌឺ វ៉លស្ទ្រីត ជឺណល (The Wall Street Journal) បានរាយការណ៍នៅសប្តាហ៍នេះ។

ក្រុងភ្នំពេញ កំពុងពឹងផ្អែកលើក្រុងវ៉ាស៊ីងតុន នូវយុទ្ធវិធី "បូកចេញសូន្យ zero-sum" ដើម្បីប្រកួតជាមួយចិនអាចរកឃើញជំហរខ្លួន ចុះខ្សោយ ប្រសិនបើរដ្ឋបាល បាយដិន លែងស្តាប់ទ្រឹស្តី ដូមីណូថ្មី។

រដ្ឋបាល បាយដិន លើកឡើងបញ្ហាផ្សេងទៀតសម្រាប់កម្ពុជាផងដែរ។ សូមរម្លឹកថា ក្រុងភ្នំពេញ បានសរសើការសម្រេចចិត្តត្រាំយកអាមេរិកចេញពីភាពជាដៃគូ Trans-Pacific ។ កម្ពុជាមិនមែនជាភាគីពាណិជ្ជកម្ម និងបានឈរបាត់សេដ្ឋកិច្ច ខណៈពេលដែលខ្លួនបានបង្កើនការវិនិយោគ និងពាណិជ្ជកម្មជាមួយអាមេរិក និងអ្នកជិតខាងខ្លួន ជាពិសេសវៀតណាម។ "ខ្ញុំអាចនិយាយដោយស្មោះត្រង់ថា ខ្ញុំចង់ឱ្យ TPP ងាប់" លោកហ៊ុន សែន បាននិយាយនៅចុងឆ្នាំ២០១៧។

ប្រសិនបើអាមេរិកត្រឡប់ទៅ TPP វិញ ដូចអ្នកខ្លះបានគិត លោកបាយដិន នឹងព្យាយាមជាការស្រមៃមួយ **តទៅទំព័រទី១៥**





"បទអត្ថាធិប្បាយ"

# គណបក្សសាធារណរដ្ឋនឹងប្រជាធិបតេយ្យនៅសហរដ្ឋអាមេរិក

ដោយ ពិន សំខុន - ថ្ងៃទី១៨វិច្ឆិកា ២០២០

គេគួរជឿដែរឬទេ ថាគណបក្សសាធារណរដ្ឋអាមេរិកាំងកំពុងនៅពីក្រោយព្រឹត្តការណ៍ដ៏រន្ធត់ស្តីពី "ការលួចសន្លឹកឆ្នោត" កាលពីថ្ងៃបោះ ឆ្នោតប្រធានា-ធិបតីអាមេរិកាំង ទី៣វិច្ឆិកា២០២០? មិនគួរឱ្យជឿទេ! ប៉ុន្តែលោកប្រធានាធិបតី ឌុណាល ត្រាំ តាំងតែពីថ្ងៃបោះឆ្នោតរួចមក នៅតែទទ្រូញថា"មានគេលួចសន្លឹកឆ្នោតរបស់លោក... លោកជាអ្នកជាប់ឆ្នោត... លោក-ទទួលបានសន្លឹកឆ្នោតច្រើនណាស់!"។ ប៉ុន្តែលទ្ធផលដែលរដ្ឋនីមួយៗប្រកាស គឺលោក ឌុណាល់ ត្រាំ ចាញ់ឆ្នោត ដោយបានតែ២៣២ដំណាង រីឯលោក បាយ ដិន បាន ៣០៦ដំណាង...ពាក្យដ៏អស់រសនៅ ពេលចាញ់ឆ្នោតហើយទៅប្តឹងដោយគ្មាននាំ ភស្តុតាងទៅតុលាការ។ ដល់ការកាត់សេចក្តីចេញមក គេបានទាត់ចោលបណ្តឹងទាំងឡាយ របស់ប្រធានាធិបតី ដោយវិនិច្ឆ័យថា "ពុំមានករណី លួចសន្លឹកឆ្នោតជាប្រព័ន្ធណាមួយនោះទេ"។

ដូច្នេះពាក្យថា "លួចសន្លឹកឆ្នោត"នេះ ចេញពីប្រធានាធិបតីអាមេរិកាំង គឺជាការប្រមាថសហរដ្ឋ-អាមេរិកនឹងពលរដ្ឋអាមេរិកាំងហើយ ទម្លាក់កិត្តិយសប្រទេសមួយនេះ ឱ្យធ្លាក់ដល់បាតនៃក្រុមប្រទេសប្រជាធិបតេយ្យនឹងជាក្រុមពុករលួយ បើប្រយោគទាំងនោះធ្វើឱ្យគេជឿ។

មិនមានតែអ្នកគាំទ្រប្រធានាធិបតីចាញ់ ឆ្នោតទេ ដែលនៅពីក្រោយលោក ត្រាំ មាន ទាំងសមាជិកគណបក្សសាធារណរដ្ឋធំៗ ដូចជា ប៉ម ប៉េអូ, មីក ម៉ាក់ខណល, ជូល្យានី... ខំប្រឹង ការពារភាព"ឡាំប៉ា" មិនព្រមទទួលចាញ់ជាមួយលោក ត្រាំ, ដែលេ-ពលនេះទើបគេដឹងថា អ្នកទាំងនោះ ហាក់ដូចជា"មិនមែនការពារប្រជា ធិបតេយ្យរបស់សហរដ្ឋអាមេរិកនោះទេ គឺខំការពារដំណែងរបស់បក្សខ្លួនទៅវិញសោះ"។ អ្នកទាំងនោះ បើប្តឹងដោយសមហេតុផល តុលាការ នឹងទទួលយកបាន, ប៉ុន្តែមតិសាធារណថា "មិនត្រឹមត្រូវទេ" សូម្បីតែសមាជិកសំខាន់ៗមួយភាគទៀត ក៏មិនចូលដៃ"ឡាំប៉ា"ជាមួយគណបក្សសាធារណរដ្ឋ




ដែរ, ទាំងនេះហើយនាំឱ្យពលរដ្ឋអាមេរិកាំងរជើបរំជួលចែកជា២ក្រុមឈ្លោះគ្នា។

សហរដ្ឋអាមេរិក មានកាងារដ៏ប្រញាប់បំផុត ២មុខ ដែលត្រូវធ្វើភ្លាមគឺ ១-ទប់ស្កាត់ "កូវីដ១៩" ដែលបានសម្លាប់ពលរដ្ឋអាមេរិកាំង២៥ម៉ឺននាក់ទៅហើយ ២-បញ្ឈូរសេដ្ឋកិច្ចប្រទេសឡើងវិញ។ "មេ-រោគ"ចម្លងជម្ងឺជិត១១ លាននាក់ហើយ ថ្នាំព្យាបាលក៏គ្មានតម្រូវឱ្យ ហាងលក់ទំនិញ ឬរោងចក្របិទទ្វារ, ម្លោះហើយ អ្នកគ្មានការធ្វើ នឹងអ្នករងគ្រោះដោយកូវីដ១៩ ឋិតនៅក្នុងភាពរវើរវាយគ្មានការគ្រប់គ្រង។ ឥឡូវដោយសារតែការញុះញង់ អ្នកបោះឆ្នោតគាំទ្រលោក ត្រាំ សហរដ្ឋអាមេរិកមានបន្ថែម "ការ-រំជើបរំជួល"មួយថ្មីទៀត។ ជំនួសដំណោះស្រាយ លើភាពចាំបាច់នោះ លោក ឌុណាល់ ត្រាំ ចំណាយពេលដ៏ច្រើនសម្រាប់តវ៉ា ដែលគ្មានមូលដ្ឋានទៅវិញ, ហើយក្រុមលោក ត្រាំ ក៏មិនអើពើនឹងភាពចាំបាច់របស់ប្រទេសដូចគ្នា... តើលោក ត្រាំ នឹងគណបក្សសាធារណរដ្ឋចង់បានអ្វី?

គណបក្សសាធារណរដ្ឋដែលធ្លាប់មានកេរឈ្មោះជាអ្នកស្នេហាជាតិបេក្ខជនម្នាក់ៗសុទ្ធតែធ្លាប់មានសមត្ថភាពនិយាយមិនលេបសម្តី ហើយ ស្អប់ខ្ពើមប្រជាភិថុត, ពេលនេះគេថា"លោកប្រ ធានាធិបតី ឌុណាល់ ត្រាំ ចុះជាមនុស្សថ្មីថ្មោង ក្នុងនយោបាយ" ប៉ុន្តែហេតុអ្វីក៏គណបក្សដែលស្នងដំណែលពីប្រធានាធិបតី អាប្រាហាម លីន កិន នេះក៏ជ្រាយដែរ, ចង់តែឈ្នះ មិនប្រមាណសមត្ថភាពរបស់ប្រធានាធាធីបតីខ្លួន ដែលចូលចិត្តនិយាយមិនពិតមានអំណួតមុខក្រាស់មានអតីតកាលមិនច្បាស់លាស់ជាវរជនស្អាតស្អំ... ទង្វើទាំងនោះហើយដែលនាំឱ្យគេមើលឃើញថា"មន្ត្រីគណបក្សសាធារណរដ្ឋ ក៏ជាក្រុមស្រឡាញ់តែដំណែងខ្ពស់ជាជាងស្រឡាញ់ប្រជាធិបតេយ្យជាងកិត្តិយសប្រជាជាតិ"។ គណបក្ស សាធារណរដ្ឋកំពុងលង់ខ្លួនដកមិនរួចពីការពារដំណែងប្រធានាធិបតីរបស់មនុស្ស ដែលសន្លឹកឆ្នោតភាគច្រើន បានបោះបង់លោក ត្រាំ ចោលនាពេលនេះ។ កិច្ចកាពារត្រូវធ្វើជូនប្រជាពលរដ្ឋបានត្រូវខកខាន នាចុងអាណត្តិលោក ត្រាំ នៅ សល់តែប្រជាភិថុតប៉ុណ្ណោះ។

កិត្តយសគណបក្សសាធារណរដ្ឋ នឹងលិច ស្រឹមប្រសិនបើគ្មានអ្នកដែលបានដកខ្លួនពីការគាំទ្រ ឌុណាល់ ត្រាំ ខ្លះទេនោះ គឺមានក្រុម អតីតប្រធានាធិបតី ប៊ូសទាំងមូល, អតីតបេក្ខជន មីត រ៉មនីយ ជាដើម ដែលបានរក្សាជំហ៊ររដើម របស់គណបក្សមិនខ្លាចខូចប្រជាប្រិយភាពពី ប្រជាពលរដ្ឋមិនខ្លាចការចំអកពីគណបក្សខ្លួនទេ... ឱ្យតែទស្សនៈយុត្តិធមិ,ទស្សនៈសហប្រជាជាតិនិយម, ទស្សនៈមនុស្សធមិនិយមនៅ តែប្រកាន់ជាមូលដ្ឋាន, ដែលទីនោះទេ គេថែ រក្សាកេរដំណែលលោក អាប្រាហាម លីនកិនជា បីតាបង្រួបបង្រួមជាតិក្នុងសង្គ្រាមស៊ីវិល។

ប្រជាពលរដ្ឋអាមេរិកាំងនឹងចងចាំយ៉ាងយូរនូវព្រឹត្តិការរារាំងលទ្ធផលនៃការបោះឆ្នោត នឹងទង្វើចំពោះសហរដ្ឋអាមេរិក របស់មហាសេដ្ឋី "អតីតពាណិជ្ជករអចលនទ្រព្យ"ដ៏ពូកែរខាង ឡើងតុលាការថា"ការប៉ុនប៉ងប្តូរលទ្ធផលនៃការ បោះឆ្នោត២០២០ ដោយឡាំប៉ា"ប្រាថ្នានៅសេដ្ឋ វិមានបន្តទៅ៤ឆ្នាំទៀត" ពួកគេនឹងបានបន្តរសម្លាប់ពលរដ្ឋដោយវ៉ាយរ៉ុស នឹងសម្លាប់សេដ្ឋកិច្ចអាមេរិកាំងយ៉ាងធ្ងន់ធ្ងរ។




មណ្ឌលពិនិត្យសុខភាពលីន
Lynn Primary Care Center
លោកវេជ្ជបណ្ឌិត ម៉ី សុខារិទ្ធ, M.D.
Sokharith Mey, M.D.
ឥឡូវនេះបើកទទួលយកអ្នកជំងឺថ្មី
Now Accepting New Patients
អាស័យដ្ឋាន
280 Union Street, Unit 402 • Lynn, MA 01901 • (781) 780-7755
ទទួលយកម៉ាសហែល, មេឌីឃែ និងធានារ៉ាប់រងសុខភាពផ្សេងៗទៀត
បុគ្គលិករបស់យើងខ្ញុំនិយាយភាសាខ្មែរ

ជំងឺទូទៅ
Family Medicine
សុខភាពផ្លូវចិត្ត
Behavioral Health
We Accept MassHealth, Medicare
and Other Health Insurances
Our Staff Speaks Khmer

តមកពីទំព័រទី ០១

## សេង ធារី មេធាវីសិទ្ធិមនុស្សសញ្ជាតិ...

បាតុកម្មដោយសន្តិវិធី និងមនុស្សជាច្រើននាក់ផ្សេងទៀតដោយសារតែការផ្សព្វផ្សាយតាមហ្វេសប៊ុក ដែលបណ្តាលឱ្យមានមនុស្ស៥៥នាក់បានជាប់ពន្ធនាគារពីបទទាក់ទងនឹងនយោបាយ។ វាជាការគាបសង្កត់ជាប្រព័ន្ធលើសកម្មជនសិទ្ធិមនុស្ស និងសង្គមស៊ីវិលកម្ពុជាជាច្រើននាក់ ប៉ុន្តែគ្មាននរណាម្នាក់បានដឹងមុនពីដីកាកោះដ៏ច្រើននេះក្នុងពេលតែមួយចំថ្ងៃវិស្សមកាលឡើយ។ សង្គមស៊ីវិល ខ្មែរ-អាមេរិក បានចាប់ផ្តើមធ្វើញត្តិមួយនៅចុងរដូវក្តៅទាក់ទិននឹងការចាប់ខ្លួនមេដឹកនាំសហជីពលោក រ៉ុង ឈុន និងសកម្មជនជាយុវជន១៤នាក់ ផ្សេងទៀត និងបានជម្រុញឱ្យសមាជិកសភា និងព្រឹទ្ធសភា ចាត់វិធានការ។

ដោយសារតែគ្រប់គ្នាជាប់រវល់ជាមួយការបោះឆ្នោតអាមេរិក លិខិតរួមមួយពីសមាជិកព្រឹទ្ធសភាពីររូប នៃរដ្ឋម៉ាសាជូសែត (Massachusetts) លោកស្រី អេលីហ្សាបែត វ៉ារេន (Elizabeth Warren) និងលោក អេដវឺត ម៉ាកឃី (Edward Markey) ព្រឹទ្ធសភា ដាយអាន ហ្វេនស្តែន (Dianne Feinstein) មកពីរដ្ឋ កាលីហ្វ័រញ៉ា តំណាងរាស្ត្រលោក អាឡាន ឡូវេនថល (Alan Lowenthal) ឡូរី ត្រាហាន (Lori Trahan) សេត មូថុន (Seth Moulton) និងលោក ថិត យូហូ (Ted Yoho) ត្រូវបានបញ្ជូនទៅរដ្ឋមន្ត្រីក្រសួងការបរទេស លោក ម៉ៃ ប៉ុមពីអូ (Mike Pompeo) ក្រោយពេលបោះឆ្នោត។ លិខិតចុះថ្ងៃទី១៦ ខែវិច្ឆិកា បានជម្រុញឱ្យលោកម៉ៃ ប៉ុមពីអូសហការប្រឹងប្រែងដាក់សម្ពាធលើរដ្ឋាភិបាលកម្ពុជាក្រោយពីមនុស្ស៥៥នាក់ត្រូវបានចាប់ខ្លួន ហើយពួកគេក៏មិនបានដឹងពីករណីថ្មីៗទៀតដែរ។ ព័ត៌មានមិនបានដល់រដ្ឋាភិបាលអាមេរិកទេ ពីព្រោះតែអាមេរិកជាប់រវល់ជាមួយការបោះឆ្នោត។ បណ្តាញសារព័ត៌មានទាំងអស់បានផ្តោតលើការប្រជែងប្រកៀកប្រកិតគ្នា ហើយជ័យជម្នះរបស់ប្រធានាធិបតី មិនទាន់ប្រកាសរហូតដល់៥ថ្ងៃក្រោយការបោះឆ្នោត។

រដ្ឋាភិបាលកម្ពុជាមិនខ្ជះខ្ជាយពេលវេលាទេ។ មនុស្សចំនួន ៦៨នាក់ត្រូវបានចោទពីបទសមគំនិតក្បត់ជាតិ នៅថ្ងៃទី៤ ខែវិច្ឆិកា (ចំថ្ងៃបោះឆ្នោតអាមេរិក) សេចក្តីជូនដំណឹងបានបិតឯនៅទីស្នាក់ការ គណៈបក្សសង្គ្រោះជាតិដែលបានបិទទ្វា នៅថ្ងៃទី១៤ ខែវិច្ឆិកា។ មនុស្សខ្លះបានទទួលការជូនដំណឹងដោយផ្ទាល់ អ្នកផ្សេងទៀតតាមរយៈការប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ។ ក្នុងពេលនេះដែរ សមាជិកសភា និងព្រឹទ្ធសភាបានរៀបចំធ្វើលិខិតមួយឆ្លើយតបទៅនាយករដ្ឋមន្ត្រី ហ៊ុន សែន និង រដ្ឋាភិបាលរបស់គាត់ផ្អែកលើព័ត៌មានចាស់ពីអង្គការយូមេនរ៉ៃវ៉ិច (Human Rights Watch) បានរាយការណ៍ថា បុគ្គល៥៥នាក់ គឺជាអ្នកទោសនយោបាយនៅត្រឹមខែតុលា ឥឡូវអាចមានច្រើនជាងមួយរយនាក់ នឹងចូលគុកនៅពេលសវនាការចាប់ផ្តើមចំថ្ងៃ Thanksgiving មានមនុស្សកាន់តែច្រើនទទួលបានដីកាកោះ។ "យើងដឹងថា នេះមិនមែនច្បាប់ទេ។ ប្រសិនបើវាជាច្បាប់ និតិរដ្ឋត្រូវបានរំលោភនៅគ្រប់ទីកន្លែង រឿងក្តីត្រូវតែទម្លាក់ចោលយោលើមូលហេតុងាយៗ។ ប៉ុន្តែវាគឺជានយោបាយ និងល្បែងអំណាច"សេង ធារី បាននិយាយ"។ វាគឺជាសវនាការបែបសំដែង ហើយខ្ញុំត្រៀមខ្លួនចូលគុក ហើយសូមចងចាំថា នេះមិនមែនតែខ្ញុំទេ សូមគិតដល់អ្នកផ្សេងទៀតដែលស្ថិតក្នុងស្ថានភាពនេះ និងមានមធ្យោបាយតិចតួចជាងខ្ញុំ ការពារខ្លួន និងសូមលើកទឹកចិត្តពួកគាត់ដោយការបន់ស្រន់"។

ជាមួយការវិវត្តន៍យ៉ាងលឿនប្រធានាធិបតីជាប់ឆ្នោត ចូ បាយដិន កំពុងរៀបចំការផ្ទេរ ហើយលោកប្រធានាធិបតីត្រាំ នៅតែកំពុងតវ៉ាលទ្ធផលឆ្នោតជាមួយការឡើងក្តីដោយប្រើប្រាស់ការអះអាងគ្មានមូលដ្ឋាន និងត្រូវបានគ្រវាត់ចោលនៅក្នុងរដ្ឋជាច្រើន នាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏កំពុងប្រើតុលាការរបស់ខ្លួនកំចាត់សមាជិកបក្សប្រឆាំង រួមទាំងព្រឹទ្ធសភា លោក ថា សេដ្ឋា ដែលបានជាប់ឆ្នោត និងបម្រើការងារពីឆ្នាំ១៩៩៦ដល់២០១៥ ផងដែរ។ គាត់គឺជាមនុស្សម្នាក់ក្នុងចំណោមអ្នកទទួលការបញ្ជារឱ្យឡើងសវនាការពីបទក្បត់ជាតិ។ ឯកឧត្តម ថាច់ សេដ្ឋា បាននិយាយទាក់ទងនឹងតុលាការថា "វាដូចជាជំនាន់ខ្មែរក្រហម វាព័ន្ធចាប់មនុស្សពីបទក្បត់ជាតិ បន្ទាប់មកប្រើតុលាការដើម្បីលុបបំបាត់ពួកគេចោល។ មិនថាអ្នកមានសិទ្ធិអ្វីទេ បើទោះជាអ្នកមានមេធាវីពីឋានសួគ៌ាក៏ដោយ យើងនឹងនៅតែមិនឈ្នះ យើងនឹងនៅតែចូលគុកនោះ គឺជារឿងពិត"។

សេង ធារី ជាពលរដ្ឋខ្មែរ-អាមេរិក បានស្នើសុំទៅអគ្គរដ្ឋទូតអាមេរិក លោក ប៉ាទ្រិក មឺហ្វី (Patrick Murphy) ឱ្យចូលរួមមើលសវនាការ នាងជឿថានឹងនិយាយក្នុងសម្លេងមួយ ហើយនាយករដ្ឋមន្ត្រី ហ៊ុន សែន អាចប្តូរទិសដៅ។ កាសែត ខ្មែរប៉ុស្តិ៍អាមេរិក បានទូរស័ព្ទទៅការិយាល័យអគ្គរដ្ឋទូត នៅទីក្រុងភ្នំពេញ ចង់ដឹងថា តើគាត់នឹងទៅចូលរួមសវនាការដែរឬទេ ប៉ុន្តែមិនអាចជួបលោកបានដើម្បីសុំយោបល់។

Jared Genser ជាមេធាវីសិទ្ធិមនុស្សដ៏ល្បីល្បាញម្នាក់បានបញ្ជូនការអំពាវនាវបន្ទាន់មួយ ជំនួសមុខឱ្យសេង ធារី កាលពីថ្ងៃច័ន្ទ ទៅអ្នករាយការណ៍ពិសេសនៃអង្គការសហប្រជាជាតិ តែនៅមិនទាន់មានការឆ្លើយតប ពីព្រោះតែថ្ងៃវិស្សមកាល Thanksgiving។

Beej Das, មេធាវីផ្នែករដ្ឋធម្មនុញ្ញអាមេរិកនិងជាអតីតមិត្តរួមថ្នាក់របស់សេង ធារី នៅសាលាច្បាប់មីស៊ីហ្គែន បាននិយាយថា "ជនដើមកំណើតខ្មែរណាក៏ដោយ គួរតែរួមដៃគ្នាគិតពីប្រទេសកម្ពុជានាពេលឥឡូវនេះ ទោះបីប្រជាជនដែលគាំទ្ររបបនេះ គួរតែគិតគូរពីសេរីភាពនៃការនិយាយស្តី ដែលលែងមានសេរីភាព។ នៅពេលវាកើតឡើង វាមិនដែលមានទីបញ្ចប់ល្អទេសម្រាប់ប្រទេស"។

តទៅទំព័រទី១២

Continued from page 01

## A Cambodian American Civil Rights Lawyer Theary C. Seng and 67 others Face Trials for Treason in Cambodia on Thanksgiving Day

mostly former CNRP members, but also includes Theary C. Seng, a Cambodian American civil rights lawyer, known as one of the most outspoken rights activists against Prime Minister Hun Sen and his government.

Human rights in Cambodia has rapidly worsened over the past three years, after the dissolution of the opposition party— the CNRP which had 55 members elected in the National Assembly. In the 2018 election, Cambodia's ruling party, the CPP has become a one party ruling state.

Since then, the regime has shutdown the free press such as the Cambodia Daily newspaper, Radio Free Asia, and Voice of Democracy; then arrested journalists, rights activists for peaceful demonstrations, and others for Facebook postings which resulted in 55 people jailed for politically motivated charges. It has been a systematic suppression of many Cambodian activists and civil society, but no one foresaw this large summon all at once around this holiday.

Cambodian American civil society has started a petition in late summer with regards to the arrest of union leader Rong Chhun and 14 other youth activists and urged their congress members and senators to take action.

Because everyone has been busy with the U.S. election, a joint letter from two Massachusetts senators, Elizabeth Warren and Edward Markey, Senator Dianne Feinstein from California, House of Rep. Alan Lowenthal, Lori Trahan, Seth Moulton, and Ted Yoho was sent to Secretary of State Mike Pompeo after the election. The letter, dated November 16, urged Secretary Pompeo to coordinate efforts to put more pressure on the Cambodian government after 55 arrests; however, they were not aware of the new cases. The news did not reach the U.S. government because the U.S has been pre-occupied with the election. All news channels were focused on the neck-to-neck race, and the presidential victory which was not declared until 5 days after the election.

The Cambodia government wasted no time. 68 people were charged with conspiracy of treason on November 4th (on U.S. election day); paper notices were posted at the closed CNRP headquarters on November 14th. Some people received their notice in person, others through announcement in the media. Meanwhile U.S. Congress members and Senators were preparing a letter in respond to Prime Minister Hun Sen and his government based on the latest information from Human Rights Watch which reported 55 individuals are political prisoners as of October—now, there could be as many more than 100 people going to prison as the trial starts on Thanksgiving day as more people received summons. "We know that this is not about law. If this was about law, due process was violated all over the place, the case should have been dismissed on that simple ground. But this is political and it's about power play" Theary C. Seng said. "It's a show trial and I am prepared to go to prison, and let's remember that this isn't about me, let's think of others who are in this situation and have less means than me to defend themselves and lift them up in our prayers".

With this fast development, while President-Elect Joe Bidden was working on making his transition, and as President Trump is still contesting the election results with lawsuits using baseless claims and having them thrown out in many states; Prime Minister Hun Sen is also using his court to get rid of the opposition party members, including former Senator Thach Setha who was elected and served from 1996 to 2015. He is among those currently ordered to stand trial for treason.

His Excellency Thach Setha said **Continued to Page 12**




**PRINT READERSHIP**
*50,000 Monthly / 600,000 Annually*
*Plus additional exposure in our online editions at khmerpostusa.com*

KhmerPost USA

**ONLINE EDITIONS AVAILABLE AT KHMERPOSTUSA.COM**

## 2020 PRINTING SCHEDULES

**EFFECTIVE FEBRUARY 1, 2020**

**ADVERTISING RATES AND SIZES**

*All ads are printed in Full Color*

| Ad Size (WxH) | 1 Issue 5% Savings | 3 Months (6 Issues) 7.5% Savings | 6 Months (12 Issues) 10% Savings | 12 Months (24 Issues) |
|---|---|---|---|---|
| Full (10" wide x 13" tall) | $460 | $2,622 | $5,106 | $9,936 |
| 1/2 (10" wide x 6.5" tall) | 310 | 1,674 | 3,441 | 6,696 |
| 1/4 (5" wide x 6.5" tall) | 165 | 940 | 1831 | 3,564 |
| 1/8 (5" wide x 3.25" tall) | 90 | 513 | 999 | 1,944 |

Your ad is also published in our online editions of the newspaper at khmerpostusa.com




**MONTHLY DISTRIBUTION**
*70+ Locations in Lowell, MA · 7,000 copies*
*25 Locations in Lynn & Revere, MA · 1,000 copies*
*25 Locations in Providence & Cranston, RI · 2,000 copies*
*Additional distribution online*

***Khmer Post USA Distribution Locations Include:***
*Households • Markets • Retail Businesses*
*Restaurants • Office Buildings • Government Offices*
*Chamber of Commerce • Buddhist Temple*
*Laundromats • And Much More*

| 2020 PRINTING DATES | ADVERTISING DEADLINE |
|---|---|
| February 15 -Friday | February 13- Thursday |
| February 29 -Saturday | February 28-Friday |
| March 09 -Monday | March 6 - Friday |
| March 23 -Monday | March 20 - Friday |
| April 06 -Monday | April 3 - Friday |
| April 20 -Monday | April 17 - Friday |
| May 04 -Monday | May 1 - Friday |
| May 18 -Monday | May 15 - Friday |
| June 1 - Monday | May 29 - Friday |
| June 15 - Monday | June 10 - Wednesday |
| July 1 - Wednesday | June 26 - Friday |
| July 15 - Wednesday | July 10 - Friday |
| August 1 - Saturday | July 27- Monday |
| August 15 - Saturday | August 10 - Monday |
| September 1 - Tuesday | August 27 - Thursday |
| September 15 - Tuesday | September 10 - Thursday |
| October 1 - Thursday | September 26 - Saturday |
| October 15 - Thursday | October 10 -Saturday |
| November 1 - Sunday | October 27 - Tuesday |
| November 15 - Sunday | November 10 - Tuesday |
| December 1 - Tuesday | November 25 - Wednesday |
| December 15 - Tuesday | December 10 - Thursday |

***Advertising deadlines are 5 business days prior to printing date.***

**CONTACT INFO**
27 Jackson Street • Unit 329 • Lowell, MA 01852
Tel: 978.677.7163 • Fax: 978.677.7092
Email: khmerpostusa@gmail.com
www.khmerpostusa.com

*Khmer Post USA is a proud member of New England Press & Newspaper Association and Greater Merrimack Valley Convention and Visitors Bureau*

Follow us @KhmerPostUSA

Follow us @KhmerPostUSA

## សេចក្ដីជូនដំណឹងស្ដីពី ការរៀបចំកិច្ចប្រជុំជាសាធារណៈ

កិច្ចប្រជុំបន្ទាប់នៃអង្គការផែនការ Middlesex Metropolitan ខាងជើងហៅកាត់ថា (NMMPO) នឹងធ្វើឡើងតាម-វីដេអូ នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ២០២០ វេលាម៉ោង២រសៀល។ កិច្ចប្រជុំ NMMPO នេះនឹងឮបច្ចុប្បន្នភាព ការកែប្រែកម្មវិធីធ្វើឱ្យល្អប្រសើឡើងការដឹកជញ្ជូន (TIP) និងថវិកាសម្រាប់គម្រោង LRTA ចំនួនពីរ។ លើសពីនេះ MPO នឹងពិចារណាគ្រប់គ្រងការអនុវត្ត និងរបាយការណ៍ ស្ដីពីសុវត្ថិភាពដឹកជញ្ជូនក្នុងតំបន់។ របៀបវារៈទាំងស្រុង អាចរកបានពី www.nmcog.org ។

**សូមបញ្ជាក់:** កិច្ចប្រជុំ NMMPO នឹងធ្វើតាមវីដេអូវេទិកា Zoom ។ ព័ត៌មានអំពីការចូលទៅកាន់កិច្ចប្រជុំនឹងដាក់ផ្សាយលើ www.nmcog.org. ។ អ្នកក៏អាចទទួលបានព័ត៌មានដោយគ្រាន់តែហៅទៅលេខ ៩៧៨-៤៥៤-៨០២១, ខេត។ ១២១ ឬអ៊ីម៉ែល jhoward@nmcog.org ។ កិច្ចប្រជុំ NM-MPO នឹងផ្ដល់កន្លែងស្នាក់នៅសមរម្យ និងជំនួយផ្នែកភាសាដោយឥតគិតថ្លៃតាមការស្នើសុំ (រួមទាំង សម្រាប់អ្នកបកប្រែភាសាសញ្ញាអាមេរិក និងភាសាផ្សេងទៀត ក្រៅពីភាសាអង់គ្លេស វីដេអូមានអក្សររត់លើអេក្រង់ មានឧបករណ៍ជំនួយឱ្យស្ដាប់ឮ និងមានសម្ភារៈច្រើនប្រភេទ)។ សម្រាប់ការស្នើសុំជំនួយ សូមទាក់ទងទៅ លោក ចាស្ទីន ហូវ៉ាដ (Justin Howard) តាមទូរស័ព្ទលេខ (978) 454-8021, ខេត។ ១២១ ឬតាម jhoward@nmcog.org ។ ការស្នើសុំគួរតែធ្វើឡើងឱ្យបានឆាប់ តាមដែលអាចធ្វើទៅបានសម្រាប់តម្រូវការសេវា និងភាសាសញ្ញា CART ឬការបកប្រែភាសា ដើម្បីត្រៀមរៀបចំឱ្យបានមុន។

## NOTICE OF PUBLIC MEETING

The next meeting of the Northern Middlesex Metropolitan Planning Organization (NMMPO) will be held virtually on December 2, 2020 at 2:00 PM. At this meeting, the NMMPO will hear updates on adjustments to the regional Transportation Improvement Program (TIP) on funding for two LRTA projects. In addition the MPO will consider performance management and the regional transportation safety report. The full agenda can be found at www.nmcog.org.

Notice: NMMPO meetings are currently being held virtually via the Zoom platform. Information about accessing the meeting will be posted at www.nmcog.org. You can also get information on meeting access by calling 978-454-8021, ext. 121 or by emailing jhoward@nmcog.org. The NMMPO provides reasonable accommodations and/or language assistance free of charge upon request (including but not limited to interpreters in American Sign Language and languages other than English, open or closed captioning for videos, assistive listening devices and alternate material formats), as available. For assistance, please contact Justin Howard at (978) 454-8021, ext. 121 or at jhoward@nmcog.org. Requests should be made as soon as possible for services requiring advanced arrangements, including sign language, CART or language translation or interpretation.

# ឌឹ ឃែមបូឌា ដេលី The Cambodia Daily

## អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី

### ក្រុមគ្រួសារអ្នកជាប់ឃុំអតីតមន្ត្រីគណបក្សសង្គ្រោះជាតិ បន្តរកកិច្ចអន្តរាគមន៍ពីព្រះមហាក្សត្រជាថ្មីទៀត

By ឌឹ ខេមបូឌា ដេលី

- November 21, 2020

សាច់ញាតិអតីតសកម្មជននិងមន្ត្រីគណបក្សសង្គ្រោះជាតិ បានប្រមូលផ្តុំគ្នាជាថ្មីនៅព្រឹកថ្ងៃសុក្រនេះក្បែរព្រះបរមរាជវាំង ដើម្បីស្វែងរកកិច្ចអន្តរាគមន៍ពីព្រះមហាក្សត្រឱ្យដោះលែងប្តី និងឪពុករបស់ពួកគេដែលកំពុងជាប់ឃុំពាក់ព័ន្ធរឿងនយោបាយ ។

សាច់ញាតិអតីតសកម្មជនបក្សនិងមន្ត្រីគណបក្សសង្គ្រោះជាតិបានស្វែងរកកិច្ចអន្តរាគមន៍ពីព្រះមហាក្សត្រសម្តេចព្រះបាទនរោត្តម សីហមុនី ចំនួន២លើក រួចមកហើយ ប៉ុន្តែត្រូវបរាជ័យដោយសារអាជ្ញាធររាជធានីភ្នំពេញរារាំង ។




យ៉ាងណាក្តីពួកគាត់ដែលភាគច្រើនជាស្ត្រីទាំងនេះទទួលបរាជ័យសារជាថ្មីទៀតក្នុងការដាក់ញត្តិថ្វាយព្រះមហាក្សត្រ ព្រោះអាជ្ញាធរខណ្ឌដូនពេញទប់ស្កាត់ និងរារាំងមិនឱ្យក្តីបំណងរបស់ពួកគេបានសម្រេចឡើយ ។ ការថ្វាយញត្តិជូនព្រះមហាក្សត្រត្រូវបរាជ័យដោយសាច់ញាតិបក្សប្រឆាំងដែលភាគច្រើនជាស្ត្រីប្រមាណ២០នាក់ បានត្រឹមតែស្រែកទាមទារឱ្យមានការដោះលែងប្តី និងឪពុករបស់ពួកគេនៅខាងក្រៅបរិវេណព្រះបរមរាជវាំង ហើយការដាក់ញត្តិនៅព្រឹកនេះមិនមានមន្ត្រីព្រះបរមរាជវាំងណាម្នាក់ចេញមកទទួលនោះឡើយ ។

ក្រុមសាច់ញាតិអតីតសកម្មជនបក្សប្រឆាំងបានងាកមកស្វែងរកព្រះរាជអន្តរាគមន៍ពីព្រះ-មហាក្សត្រវិញនេះ ក្រោយពីពួកគេបរាជ័យក្នុងការទាមទារឱ្យតុលាការ និងប្រមុខរដ្ឋាភិបាលដោះលែងឪពុក និងស្វាមីរបស់ខ្លួនឱ្យមានសេរីភាពវិញ ព្រមទាំងទម្លាក់ចោលការចោទប្រកាន់ដែលមានចរិកនយោបាយនេះ ។ ពួកគាត់អះអាងថា អ្នកជាប់ឃុំទាំងនោះមិនបានប្រព្រឹត្តខុសដូចការចោទប្រកាន់នោះឡើយ ។

អតីតមន្ត្រីគណបក្សសង្គ្រោះជាតិដែលកំពុងជាប់ឃុំត្រូវបានតុលាការចោទប្រកាន់ពីបទ "ញុះញង់ និងរួមគំនិតក្បត់ ព្រមទាំងបទញុះញង់ឱ្យកងទ័ពមិនស្តាប់បញ្ជា ពាក់ព័ន្ធសំណុំរឿងវិលចូលស្រុករបស់លោក សម រង្ស៊ី មេដឹកនាំអតីតគណបក្សសង្គ្រោះជាតិ កាលពីឆ្នាំ២០១៩។

សហរដ្ឋអាមេរិក កាលពីថ្ងៃទី១៦ខែវិច្ឆិកា តាមរយៈស្ថានទូតរបស់ខ្លួនប្រចាំកម្ពុជាបានអះអាងថា ខ្លួនកំពុងតាមដានដោយយកចិត្តទុកដាក់បំផុត លើករណីបណ្តឹងតុលាការ ដែលមានចំនួនកាន់តែច្រើនឡើង ទៅលើសកម្មជនក្នុងសង្គមស៊ីវិល អ្នកសារព័ត៌មាន និងអ្នកគាំទ្រនៃគណបក្សនយោបាយធំជាងគេមួយរបស់ប្រទេសកម្ពុជា គឺគណបក្សសង្គ្រោះជាតិកម្ពុជា ។

ការលើកឡើងនេះ ក្រោយពេលតុលាការក្រុងភ្នំពេញបានចេញដីកាកោះហៅសកម្មជនសិទ្ធិមនុស្ស ពិសេសអតីតមន្ត្រី និងសកម្មជនគណបក្សសង្គ្រោះជាតិរាប់សិបនាក់ជាបន្តបន្ទាប់ឱ្យចូលខ្លួនបំភ្លឺជុំវិញការចោទប្រកាន់ឧបឃាត ឬប៉ុនប៉ងធ្វើរដ្ឋប្រហារ ។ បទរួមគំនិតក្បត់ និងបទញុះញង់ឱ្យប្រព្រឹត្តបទល្មើសជាដើម ។

អាមេរិកអះអាងថា សេរីភាពក្នុងការជួបប្រមូលផ្តុំគ្នា និងសេរីភាពក្នុងការសម្តែងមតិ ព្រមទាំងការអត់ឱនចំពោះមតិប្រឆាំង គឺមានសារសំខាន់បំផុត ចំពោះដំណើរការលទ្ធិប្រជាធិបតេយ្យពិតប្រាកដមួយ ។ ជាមួយគ្នានេះ សហរដ្ឋអាមេរិក អំពាវនាវឱ្យអាជ្ញាធរលោក ហ៊ុន សែន ការពារសេរីភាពទាំងនេះ ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា ។

លើសពីនេះ ត្រូវប្រកាន់ជំហានប្រកបដោយអត្ថន័យក្នុងការបើកឡើងវិញ នូវលំហនយោបាយ និងលំហសម្រាប់ពលរដ្ឋនៅក្នុងអំឡុងពេលឈានទៅរកការបោះឆ្នោតឃុំសង្កាត់ ឆ្នាំ២០២២ និងការបោះឆ្នោតជាតិឆ្នាំ២០២៣ ។

### លោក ហ៊ុន សែនបានសម្រេចចិត្ត ក្នុងការប្រកាសបិទបញ្ចប់ព្រឹត្តការណ៍ ៣វិច្ឆិកា ខណៈវិធានសុវត្ថិភាពនៅរក្សាដូចដើមដដែល

By ឌឹ ខេមបូឌា ដេលី

-November 21, 2020

លោក ហ៊ុន សែន បានប្រកាស បិទបញ្ចប់ព្រឹត្តការណ៍ ៣វិច្ឆិកា ដោយជោគជ័យ ត្បិតស្ថានភាពនៃការរីករាលដាលនៃវីរុសកូវីដ១៩ បានធូរស្បើយជាបន្តបន្ទាប់ ខណៈរដ្ឋាភិបាលកម្ពុជាអាចគ្រប់គ្រងបានទាំងស្រុង ដោយមិនមិនមានការធ្វេសប្រហែសនាំឱ្យប៉ះពាល់ដល់អាយុជីវិតប្រជាពលរដ្ឋ ឬមន្ត្រី



រាជការណាម្នាក់ពីការកម្រើកជាថ្មីនៃវីរុសនេះឡើយ ។

លើកឡើងក្នុងខ្សែរអាត់សំលេងដែលមានរយៈពេលជាង៦នាទី កាលពីយប់ថ្ងៃទី១៨ វិច្ឆិកា នេះ ប្រមុខរដ្ឋាភិបាលកម្ពុជាលោក ហ៊ុន សែន បានបញ្ជារឱ្យរដ្ឋមន្ត្រីក្រសួងពាក់ព័ន្ធនានា ក្នុងនោះមានរដ្ឋមន្ត្រីក្រសួងអប់រំជាដើមបើកគ្រឹះស្ថានអប់រំក្នុងរាជធានីភ្នំពេញដែលបានបិទក្រោយព្រឹត្តការណ៍ ៣វិច្ឆិកា និងឱ្យបើកឡើងវិញនៅថ្ងៃទី២៣ វិច្ឆិកា ខាងមុខនេះ ។ លោកក៏បានអនុញ្ញាតិឱ្យបើកស្តាតអូរឡាំពិកសារមន្ទីរ និងរោងភាពយន្តទាំងអស់ឱ្យដំណើរការឡើងវិញប៉ុន្តែត្រូវអនុវត្តវិធានសុវត្ថិភាពឱ្យបានត្រឹមត្រូវ និងហ្មត់ចត់ជាទីបំផុត ក្នុងការរក្សាគម្លាតសុវត្ថិភាពសង្គម និងសុវត្ថិភាពបុគ្គលតាមការណែនាំរបស់ក្រសួងសុខាភិបាល ។

លោក ហ៊ុន សែន បញ្ជាក់ថា អាជ្ញាធរមូលដ្ឋានទាំងអស់ត្រូវបើកទូលាយ ដើម្បីឱ្យពលរដ្ឋអាចចូលរួមក្នុងពិធីសាសនាពិធីបុណ្យទាន និងកម្មវិធីអាពាហ៍ពិពាហ៍ជាលក្ខណៈប្រពៃណី ដូចធម្មតាឡើងវិញផងដែរ ប៉ុន្តែពួកគេត្រូវគោរពតាមការហាមប្រាម និងសេចក្តីណែនាំរបស់ក្រសួងសុខាភិបាលដែលបានប្រកាសមុនព្រឹត្តការណ៍ ៣វិច្ឆិកា ដដែល ។

ទោះយ៉ាងណាក៏ដោយ លោក ហ៊ុន សែន ព្រមានថា មន្ត្រីអាជ្ញាធរ ដែលមានបងប្អូនកំពុងធ្វើចត្តាឡីស័កដែលមិនទាន់ដល់ថ្ងៃត្រូវបញ្ចប់ត្រូវណែនាំពួកគេ បន្តធ្វើចត្តាឡីស័កឱ្យបានត្រឹមត្រូវ បើមិនដូច្នេះទេ នឹងត្រូវប្រឈមការធ្វើចត្តាឡីស័កឡើងវិញ ត្បិតក្រសួងសុខាភិបាលបានកំណត់រយៈពេល១៤ថ្ងៃ គឺចាប់ពីថ្ងៃយកសំណាកដំបូងមកធ្វើតេស្ត ។

ការប្រកាសបញ្ចប់ព្រឹត្តការណ៍ ៣វិច្ឆិកា នេះធ្វើឡើងក្រោយក្រសួងសុខាភិបាលកម្ពុជាអាចគ្រប់គ្រងបានទាំងស្រុងអ្នកដែលបានពាក់ព័ន្ធក្នុងព្រឹត្តការណ៍នេះ ព្រមទាំងបានយកមកធ្វើតេស្តវត្ថុសំណាក និងបានធ្វើចត្តាឡីស័ក ទៅតាមលក្ខខណ្ឌយ៉ាងត្រឹមត្រូវជាទីបំផុត ។

ពាក់ព័ន្ធនឹងបញ្ហានេះ ក្រសួងសុខាភិបាលអះអាងថា ក្រសួងនឹងបញ្ចប់ការធ្វើតេស្ត និងការធ្វើចត្តាឡីស័កអ្នកដែលបានប៉ះពាល់ក្នុងព្រឹត្តិការណ៍ ៣វិច្ឆិកា ដោយផ្ទាល់ និងដោយប្រយោល នៅថ្ងៃទី២៥ វិច្ឆិកា ខាងមុខនេះ ។

ក្រសួងបានបញ្ជាក់ថា អ្នកដែលបានប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលក្នុងព្រឹត្តការណ៍ ៣វិច្ឆិកា មានចំនួនប្រមាណជាង៣ពាន់នាក់ ក្នុងនោះមានអ្នកជាសះស្បើយ និងអ្នកដែលកំពុងរង់ចាំធ្វើតេស្ត និងធ្វើចត្តាឡីស័កជាបន្តបន្ទាប់ ។

ក្នុងសេចក្តីប្រកាសព័ត៌មាននៅថ្ងៃ១៩ វិច្ឆិកា នេះក្រសួងបញ្ជាក់ថាអ្នកដែលបានប៉ះពាល់ដោយផ្ទាល់ និងដោយប្រយោលក្នុងព្រឹត្តការណ៍នេះ គឺស្ថិតក្នុងរាជធានីខេត្តចំនួន១១ រួមមាន រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ កំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តកែប ខេត្តព្រះសីហនុ ខេត្តកំពង់ចាម ខេត្តព្រះវិហារ និងខេតរតនៈគិរី ។ ដោយឡែកជនជាតិហុងគ្រីចំនួន៣នាក់រួមបញ្ចូលទាំង អគ្គរដ្ឋទូតហុងគ្រីផងដែរ ដែលបានរកឃើញវិជ្ជមានវីរុសកូវីដ១៩ ហើយកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាព ខ្មែរ-សូវៀត ដើម្បីតាមដានសុខភាពងបន្ត ។

ពាក់ព័ន្ធនឹងការបិទបញ្ចប់ព្រឹត្តការណ៍ ៣ វិច្ឆិកា នៅថ្ងៃទី១៩ វិច្ឆិកា នេះ លោក ហ៊ុន សែន បានបញ្ជាក់ថា លទ្ធផលនៃការធ្វើតេស្តលើកទី៤ របស់លោក និងក្រុមគ្រួសារ ព្រមទាំងអ្នកពាក់ព័ន្ធ គឺអវិជ្ជមានទាំងអស់ ហើយលោកនឹងចេញបំពេញការងារដូចធម្មតាឡើងវិញនៅថ្ងៃនេះផងដែរ ។

# ឌឹ ឃែមបូឌា ដេលី The Cambodia Daily


## អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី

### អាមេរិកកំពុងតាមដានយ៉ាងយកចិត្តទុកដាក់ ករណីបណ្តឹងតុលាការ ទៅលើក្រុមប្រឆាំង ដែលមានចំនួនកាន់តែច្រើនឡើង

By ឌឹ ខេមបូឌា ដេលី

- November 20, 2020

សហរដ្ឋអាមេរិកអះអាងថា ខ្លួនកំពុងតាមដានដោយយកចិត្តទុកដាក់បំផុត លើករណីបណ្តឹងតុលាការ ដែលមានចំនួនកាន់តែច្រើនឡើង ទៅលើសកម្មជនក្នុងសង្គមស៊ីវិល អ្នកសារព័ត៌មាន និងអ្នកគាំទ្រនៃគណបក្សនយោបាយធំជាងគេមួយរបស់ប្រទេសកម្ពុជា គឺគណបក្សសង្គ្រោះជាតិកម្ពុជា ។

ការលើកឡើងនេះ ក្រោយពេលតុលាការដោយអត្ថន័យក្នុងការបើកឡើងវិញ នូវលំហនយោបាយ និងលំហសម្រាប់ពលរដ្ឋ នៅក្នុងអំឡុងពេលឈានទៅរកការបោះឆ្នោតឃុំសង្កាត់ ឆ្នាំ២០២២ និងការបោះឆ្នោតជាតិ ឆ្នាំ២០២៣ ។

កាលពីថ្ងៃទី១៦ខែវិច្ឆិកានោះដែរ ក្រុមអ្នកជំនាញអង្គសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សបានសម្តែងក្តីបារម្ភជាថ្មីទៀតជុំវិញការធ្វើទុក្ខបុកម្នេញទៅលើសង្គមស៊ីវិល និងការចាប់ឃុំខ្លួនអ្នកការពារសិទ្ធិមនុស្ស ដែលមានលក្ខណៈជាប្រព័ន្ធ ។

ក្នុងសេចក្តីថ្លែងការណ៍ទីក្រុងហ្សឺណែវរបស់



ក្រុងភ្នំពេញបានចេញដីកាកោះហៅសកម្មជនសិទ្ធិមនុស្ស ពិសេសអតីតមន្ត្រី និងសកម្មជនគណបក្សសង្គ្រោះជាតិរាប់សិបនាក់ជាបន្តបន្ទាប់ឱ្យចូលខ្លួនឆ្លើយបំភ្លឺជុំវិញការចោទប្រកាន់ឧបឃាត ឬការប៉ុនប៉ងធ្វើរដ្ឋប្រហារ ។ បទ រួមគំនិតក្បត់ និងបទញុះញង់ឱ្យប្រព្រឹត្តបទល្មើសជាដើម ។

ទំព័រហ្វេសប៊ុករបស់ស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជាកាលពីថ្ងៃទី១៦ ខែវិច្ឆិកា បានអះអាងថា សេរីភាពក្នុងការជួបប្រមូលផ្តុំគ្នា និងសេរីភាពក្នុងការសម្តែងមតិ ព្រមទាំងការអត់ឱនចំពោះមតិប្រឆាំង គឺមានសារសំខាន់បំផុត ចំពោះដំណើរការលទ្ធិប្រជាធិបតេយ្យពិតប្រាកដមួយ ។

ជាមួយគ្នានេះ សហរដ្ឋអាមេរិក អំពាវនាវឱ្យអាជ្ញាធរលោកហ៊ុន សែន ការពារសេរីភាពទាំងនេះ ដូចដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។ លើសពីនេះ ត្រូវប្រកាន់ជំហានប្រកបក្រុមអ្នករាយការណ៍ពិសេស អង្គការសហប្រជាជាតិបានអំពាវនាវឱ្យរដ្ឋាភិបាលលោក ហ៊ុន សែន បញ្ឈប់ជាបន្ទាន់នូវការឃុំខ្លួនដែលមានលក្ខណៈជាប្រព័ន្ធ និងការផ្តន្ទាទោសព្រហ្មទណ្ឌដល់អ្នកការពារសិទ្ធិមនុស្ស ព្រមទាំងការប្រើប្រាស់កម្លាំងហួសប្រមាណប្រឆាំងនឹងពួកគេ ។

យ៉ាងណាភ្លាមៗក្រោយសេចក្តីថ្លែងការណ៍នេះចេញ អ្នកនាំពាក្យក្រសួងយុត្តិធម៌ និងជាអនុប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា លោក ជិន ម៉ាលីន ថា របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិអំពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា មិនមានមូលដ្ឋានគ្រប់គ្រាន់និងគ្រប់ជ្រុងជ្រោយក្នុងការសន្និដ្ឋាន និងវាយតម្លៃពីស្ថានភាពអ្នកការពារសិទ្ធិមនុស្សនៅកម្ពុជានោះទេ ។

អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិឱ្យដឹងថា អ្នកការពារសិទ្ធិមនុស្សយ៉ាងហោចណាស់មានចំនួន២១នាក់ បានទទួលរងការគំរាមកំហែង ការចាប់ខ្លួននិងការឃុំខ្លួនដោយបំពានក្នុងរយៈពេល៣ខែកន្លងមកនេះ ។

ក្នុងនោះ មានមនុស្សចំនួន១២នាក់ កំពុងស្ថិតនៅក្នុងការឃុំខ្លួនជាបណ្តោះអាសន្ន ហើយត្រូវបានបដិសេធសំណើសុំនៅក្រៅឃុំរបស់ពួកគេ ហើយពួកទាំងនោះ កំពុងប្រឈមនឹងការចោទប្រកាន់នានា ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល២ឆ្នាំ ប្រសិនបើរកឃើញថាពួកគេប្រព្រឹត្តដូចការចោទប្រកាន់ ។

### ក្រសួងកសិកម្ម ព្រមានចាត់វិធានការច្បាប់ចំពោះក្រុមហ៊ុន ធ្វើអាជីវកម្មឈើមួយនៅខេត្តព្រះវិហារ

By ឌឹ ខេមបូឌា ដេលី

- November 20, 2020

រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទអះអាងថា ខ្លួននឹងចាត់វិធានការច្បាប់ចំពោះក្រុមហ៊ុនមួយឈ្មោះ ម៉ាឃល ឡូជីស្ទីក ដែលត្រូវបានអនុញ្ញាតឱ្យធ្វើអាជីវកម្មឈើផ្នែកខ្លះក្នុងបរិវេណដីសម្បទានសេដ្ឋកិច្ចមួយក្បែរតំបន់ព្រៃឡង់ ប្រសិនបើរកឃើញថាពួកគេបានដើរផ្ទុយពីអ្វីដែលបានអនុញ្ញាត ។

អាជីវកម្មឈើក្នុងអនុតំបន់២ អនុតំបន់៣ និងអនុតំបន់៤ ក្នុងបរិវេណដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ភីអិនធី (PNT) ស្របតាមលទ្ធផលសារពើភ័ណ្ឌប៉ាន់ស្មាន ធនធានព្រៃឈើ ប៉ុន្តែត្រូវអនុវត្តតាមនីតិវិធីជាធរមាន ដែលមានការប្រមូលផលអនុផលព្រៃឈើ ស្ថិតនៅក្នុងឃុំរវៀបរយ ស្រុករវៀង ខេត្តព្រះវិហារ ។

រដ្ឋបាលព្រៃឈើបញ្ជាក់ថា ក្រុមហ៊ុន ម៉ាឃល ឡូជីស្ទីក មួយនេះទើបចុះធ្វើការប្រមូលផល អនុ



សេចក្តីប្រកាសព័ត៌មានរបស់រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម កាលពីថ្ងៃទី១៧ខែវិច្ឆិកា បានលើកឡើងថា ក្នុងពេលថ្មីៗនេះ នៅលើបណ្តាញសារព័ត៌មានក្នុងស្រុកមួយចំនួន បានផ្សព្វផ្សាយព័ត៌មានថា មានក្រុមហ៊ុនមួយកំពុងធ្វើសកម្មភាពកាប់បំផ្លាញព្រៃឈើយ៉ាងសកម្ម ។ លើសពីនេះក្រុមហ៊ុននោះ ដឹកជញ្ជូនសុទ្ធតែរថយន្តបាកុង ហើយមានឃ្លាំងស្តុកឈើ និងរោងម៉ាស៊ីនរ៉ៃ នៅចំណុចបាក់កន និងភូមិស្រែ ឃុំរវៀបរយ ស្រុករវៀង ខេត្តព្រះវិហារ ។

ពាក់ព័ន្ធបញ្ហានេះ រដ្ឋបាលព្រៃឈើបំភ្លឺថា កាលពីថ្ងៃទី២៦ខែមិថុនា ឆ្នាំ២០២០ ក្រសួងកសិកម្មបានអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាឃល ឡូជីស្ទីក បង់ថ្លៃសួយសារ និងបុព្វលាភជូនរដ្ឋ ព្រមទាំងធ្វើការកាប់ ប្រមូលផល អនុផលព្រៃឈើ ឬធ្វើផលព្រៃឈើកាលពីថ្ងៃទី១២ ខែវិច្ឆិកាឆ្នាំ២០២០ នេះប៉ុណ្ណោះ ។

យ៉ាងនេះក្តី ប្រភពដដែលអះអាងថា ក្នុងករណីរកឃើញថា ការប្រមូលផលអនុផលព្រៃឈើ របស់ក្រុមហ៊ុន ម៉ាឃល ឡូជីស្ទីក មិនបានត្រឹមត្រូវទៅតាមគោលការណ៍អនុញ្ញាត និងច្បាប់ស្តីពីព្រៃឈើនោះ រដ្ឋបាលព្រៃឈើនឹងចាត់វិធានការច្បាប់តែម្តង ។

សកម្មជនការពារព្រៃឈើ លោក ហេង ស្រស់ លើកឡើងថា ក្រសួងមិនគួរផ្តល់ឱកាសឱ្យក្រុមហ៊ុនទាំងនោះទៀតទេ ព្រោះកាលពីឆ្នាំ២០១៩ គឺមានករណីកាប់ឈើយ៉ាងសម្បើម ប៉ុន្តែក្រសួងនៅតែធ្វើព្រងើយ ដោយមិនព្រមចាត់វិធានការច្បាប់នោះឡើយ ។

តមកពីទំព័រទី ០៥

## បុណ្យឯករាជ្យ៩វិច្ឆិកា ឆ្នាំ២០២០...

ព្រះបាទអង្គឌួងបានសរសេរ"សារសម្ងាត់"មួយទៅស្តេចចក្រភពបារាំង"ណាប៉ូ លេអុង៣" សុំគេឱ្យមកជួយរំដោះកម្ពុជា ដោយគិតថា ប្រទេសខ្មែរនឹងត្រូវរលាយហើយ, ឆ្នាំ១៨៥៣ ទើបបានដំណឹងមកវិញតាមរយៈទស្សនកិច្ចរបស់អាចារ្យកាតូលិកឈ្មោះ"ម៉ុងសេញ៉រ មីស"។ ទស្សនៈកិច្ចនោះ បានធ្វើឱ្យស្យាមសង្ស័យ ដោយមានការរំជើបរំជួលតាមជនបទបណ្តាលឱ្យស្តេចស្យាមចាប់ចៅហ្វាយខេត្តខ្មែរខ្លះយកទៅសម្លាប់ចោល។

បែកការខ្លះមែន ប៉ុន្តែ១០ឆ្នាំក្រោយមក ឆ្នាំ១៨៦៣ នាវាចម្បាំង៥០០គ្រឿងរបស់ទាហ៊ានចក្រភពបារាំង បានមកចូលសំចតនៅជ្រោយតុងកឹងនៃប្រទេសវៀតណាមសព្វថ្ងៃ ។ ពេលនោះព្រះបាទអង្គឌួងបានចូលទីវង្គត់ទៅហើយ តែបានលើកព្រះបាទនរោត្តមជាព្រះរាជ្យបុត្រច្បងស្នងរាជ្យជាអ្នកឡើងគ្រងរាជ្យបន្តរួចជាស្រេចដែរ។ មិនមានសមត្ថភាពចម្បាំងតទល់នឹងបារាំងប្រទេសពាបានចុះហត្ថលេខាចុះចាញ់ មាន២គឺវៀតណាមនឹងឡាវ ឋិតនៅជា"អាណានិគមបារាំង Colonial" ចំណែកខ្មែរឋិតនៅជា"អាណាព្យាបាលបារាំង Protectorate"ដោយសារតែព្រះរាជសារសម្ងាត់របស់ស្តេចអង្គឌួងកាលពី១០ឆ្នាំមុននោះ។

ស្ថានភាពកម្ពុជា ពេលបារាំងចូលមកដល់ មានរចនាសម្ព័ន្ធជាកុលសម្ពន្ធនៅឡើយ មានប្រើភាសាខ្មែរជាគោល តែក៏មានគ្រាមភាសាច្រើនដែរ តែកាន់សាសនាព្រះពុទ្ធ ដែលក្រុមព្រះសង្ឃមានឥទ្ធិពលលើប្រជារាស្ត្រច្រើន។ គ្មាន



សេដ្ឋកិច្ច ឬកសិកម្មជាជន្ទល់នៃជាតិទេ បារាំងបាននាំចូលនូវដំណាំកៅស៊ូ, ភ្ជាប់សាលារៀននឹងវប្បធម៌ទៅនឹងមហាវិទ្យាល័យ"ចុងបូព៌ា Ecole extreme orient"បារាំង ដើម្បីកាអប់រំទាន់សម័យនឹងបង្កើតក្របខណ្ឌគ្រូបង្រៀន ដែលជាទូទៅសាលារៀនផ្ញើរនឹងវត្តអារាម ហើយព្រះសង្ឃជាគ្រូបង្រៀន, នៅមានកិច្ចការថែរក្សាប្រាសាទអង្គរវត្ត ដែលទ្រុឌទ្រោម និងបាក់បែកជាច្រើនអន្លើដោយវិស្វករ-ស្ថាប័ត្យករ-នឹងវិចិត្តករមកពីមហាវិទ្យាល័យចុងបូព៌ា អស់រយៈពេលជាង៦០ឆ្នាំ- ហើយដែលសំខាន់បំផុតនោះ គឺជួយរៀបចំរចនាសម្ព័ន្ធប្រទេសឱ្យទាន់សម័យជាមួយនឹងព្រះមហាក្សត្រ ហើយក៏មានបញ្ជូននិស្សិតទៅរៀននៅមហាវិទ្យាល័យធំៗនៅប្រទេសបារាំង ដើម្បីឱ្យមកជួយក៏សាងប្រទេសនៅពេលត្រឡប់មកវិញ។

**តើកម្ពុជាបានឯករាជ្យដោយរបៀបណា?**

ឯកសារបារាំងនិយាយថា"ប្រជារាស្ត្រខ្មែរជាប្រជារាស្ត្រស្លូតត្រង់លើកដំកើងវប្បធម៌ខ្លួន មោទនភាពនឹងប្រាង្គប្រាសាទដ៏សន្ធឹកសន្ធាប់ មិនសូវឆ្លាតវៃ តែស្មោះត្រង់នឹងទំនាក់ទំនងខ្លួនណាស់..."។ តែទោះជាយ៉ាងនេះក្តីបន្ទាប់ពីសង្គ្រាមលោកលើកទី១មក មានការរំជើបរំជួលបះបោរក្នុងប្រទេសទាមទាឯករាជ្យភាពពីបារាំងរជ្ជកាលព្រះបាទស៊ីសុវត្ថិ ។ ពេលនោះជប៉ុនបានវាយចូលកាន់កាប់ប្រទេសចិននៅឆ្នាំ១៩៤០ ជាចលនាពង្រីកសង្គ្រាមចេញពីចិនឆ្ពោះមកកាន់ឥណ្ឌូចិនទៀត ។ លោក សឺង ង៉ុកថាញ់ ដែលទទួលបានបរិញ្ញាប័ត្រច្បាប់ពីប្រទេសបារាំងដំបូងគេមិនបានបំរើខ្មែរជាមួយបារាំងទេ តែបានផ្ជាប់ទំនាក់ទំនងជាមួយជប៉ុន ដែលចង់ឱ្យខ្មែររំដោះខ្លួនចេញពីបារាំងទៅវិញ។ ចលនាបះបោរនោះ មានអាចារ្យ ហែម ជៀវ, អាចារ្យ សួរ ... មានទាំងបាតុកម្មព្រះសង្ឃវត្តឧណ្ណាលោម...ដែលត្រូវគ្នានឹងការឃោសនារបស់កាសែត"ណាងារាវ៉ាតា" ចេញផ្សាយនៅពេលនោះដោយ សឺង ង៉ុកថាញ់។ ដំណើរប្រឆាំងនឹងបារាំង ថាចង់បានឯករាជ្យនៅកម្ពុជានោះ បានត្រូវបារាំងចាប់ខ្លួន ដាក់ទោសជាបន្តបន្ទាប់។

ឆ្នាំ១៩៤១ ព្រះមហាក្សត្រនរោត្តម សីហនុ បានឡើងគ្រងរាជ្យ ក្នុងព្រះជន្មាយុ១៨វស្សា ដោយការតែងតាំងរបស់បារាំង ដែលបានយល់ឃើញថា ព្រះអង្គម្ចាស់អង្គនេះ មានព្រះបីតា ព្រះបាទ សុរាម្រឹត ជាខ្សែនរោត្តមនឹងព្រះមាតា កុសុមៈ នារីរ័ត ជាខ្សែស៊ីសុវត្ថិ ដូច្នេះអាចបញ្ចប់ទំនាស់ទាំងឡាយ ដែលអាចមានរវាងព្រះញាតិវង្សទាំង២ ដែលចង់បានដំណែងដ៏ខ្ពង់ខ្ពស់នេះ សម្រាប់ខ្សែខ្លួនឯងបាន។ ស្របទៅតាមអត្ថន័យនៃរដ្ឋធម្មនុញ្ញថ្មីដែលចែងថា"ព្រះមហាក្សត្រគ្រងរាជ្យអាស្រ័យធម្មនុញ្ញ" ប៉ុន្តែប្រទេសពុំទាន់បានឯករាជ្យ ជាផ្លូវការនៅឡើយទេ- មានច្បាប់ទម្លាប់ខ្លះៗហើយ មានមហាមន្ត្រី មានទីប្រឹក្សាព្រះមហាក្សត្រ មានមន្ត្រីរាជការ ដែល

**តទៅលេខក្រោយ**

តមកពីទំព័រទី ០៨

## សេង ធារី មេធាវីសិទ្ធិមនុស្សសញ្ជាតិ...

ក្នុងបទសម្ភាសមួយជាមួយកាសែតខ្មែរប៉ុស្តិ៍អាមេរិក Jared បាននិយាយថា "ខ្ញុំនឹងខិតខំអស់លទ្ធភាព ប្រសិនបើ សេង ធារី ត្រូវឃុំខ្លួន ធ្វើយ៉ាងណាឱ្យរឿងរ៉ាវរបស់នាងមានគេដឹងឮនៅជុំវិញពិភពលោក។ នាងកំពុងឆ្លងកាត់។ ធានាថា យើងនៅតាមពីក្រោយគាត់ និងក្រុមគ្រួសារគាត់តាមរយៈការដាក់ទណ្ឌកម្មបង្កកទ្រព្យសម្បត្តិ ធ្វើឱ្យគាត់ និងរបបគាត់ទទួលខុសត្រូវ ជាក់ស្តែងមានគោលដៅបង្ខំគាត់ឱ្យបន្ទន់ និងថយក្រោយពីការសង្កត់សង្កិន"។

"និយាយអំពីក្បត់ជាតិ។ លោក ហ៊ុន សែន គួរតែកាត់ទោសពីបទក្បត់ជាតិ ពីព្រោះអំពើក្បត់ជាតិ គឺការលក់ព្រលឹងជាតិឱ្យបរទេស" ធារីបាននិយាយ។

ក្នុងខែតុលាព្រះមហាក្សត្យ នរោត្តម សីហមុនី បានចំណាយពេលជាច្រើននៅចិន ក្រោយពីនាយករដ្ឋមន្ត្រីបានណែនាំកូនប្រុសរបស់លោក ឈ្មោះ ហ៊ុន ម៉ាណែត ជាឧត្តមសេនីយ៍កងទ័ពកម្ពុជា ទៅលោក ស៊ី។ ដូចបានបង្ហាញនាខែកន្លងមកថ្មីៗនេះ បានជ្រើសរើសសំឡឹងទៅចិន និងព្រងើយកន្តើយដាក់អាមេរិក និងសហគមន៍អ៊ឺរ៉ុប។ ជាការកត់សំគាល់ថា ក្មពុជាជំពាក់អាមេរិកជាង៥០០លានដុល្លារជាកម្ចី ក្រោមរដ្ឋាភិបាលលន់ ណុលពីឆ្នាំ១៩៧០ដល់១៩៧៥ និងជំពាក់រុស្ស៊ី មួយពាន់ប្រាំរយលានដុល្លារអំឡុងពេលវៀតណាមកាន់កាប់ពីឆ្នាំ១៩៧៥ដល់១៩៨៩។ ផ្ទុយទៅវិញ ចិនបានលុបចោលបំណុលដែលបានខ្ចីអំឡុងពេលសម័យខ្មែរក្រហម ពីឆ្នាំ១៩៧៥ដល់១៩៧៩។ ប៉ុន្មានខែនាពេលថ្មីៗនេះ ចិនបានឈានជើចូលកម្ពុជាកសាងព្រលានយន្តហោះ និងជំនួញ។ គោលនយោបាយកម្ពុជាសម្រេបតាមជាមួយចិននៅលើគោក និងត្រូវបានសហគមន៍អន្តរជាតិមើលរំលង នាយករដ្ឋមន្ត្រីកំពុងធ្វើការបំពេញសន្ធិសញ្ញាឆ្នាំ២០០៥ជាមួយវៀតណាម មិនអើពើ និងរំលោភកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ស្តីពីកម្ពុជា។ ប៉ុន្មានខែនាពេលថ្មីៗនេះ ប៉ុស្តិ៍នៅតាមព្រំប្រទល់ វៀតណាម ត្រូវបានគេរាយការណ៍មកថាបានរំកិលចូលទឹកដីប្រទេសកម្ពុជាហើយ អ្នកភូមិបានរាយការណ៍ពីការបាត់បង់ដី។ លោក រ៉ុង ឈុន និងអ្នកគាំទ្រលោកបានផ្សព្វផ្សាយត្រូវបានចាប់ខ្លួន និងដាក់គុកដោយសារតែការនិយាយអំពីបញ្ហាព្រំដែនជាមួយប្រទេសវៀតណាម។

Continued from page 08

## A Cambodian American Civil Rights Lawyer Theary C. Seng and 67 others Face Trials for Treason in Cambodia on Thanksgiving Day

regarding the court "it's like in Khmer Rouge era, they round up people for treason, then use their court to eliminate them. I was accused of treason. I asked now who have I conspired to commit treason for?"



Theary C. Seng gives interview to media outside of Phnom Penh court 11/26/2020

Theary C. Seng, as a U.S. citizen, requested U.S. Ambassador Patrick Murphy to appear in court, she believed that will speak volumes and Prime Minister Hun Sen may change his course. Khmer Post USA called the U.S. Ambassador's office in Phnom Penh to see if he will attend the trial but was not able to reach him for comments.

Jared Genser, a well known international human rights lawyer, represents Theary C. Seng pro bono sent out an urgent action appeal on Monday to the United Nations special rapporteur — there has been no response because of the Thanksgiving holiday.

Beej Das, U.S. Constitutional lawyer and Theary C. Seng's former classmate at Michigan Law School said "any Cambodian descendent should be up-in-arms about Cambodia right now, even people who support the regime should be concerned when free speech is no longer free. When this

**Continued to Page 15**

**តើអ្នកកំពុងជួបការលំបាកក្នុងការបង់ថ្លៃជួល ឬបញ្ចាំដោយសារ COVID-19 ដែរឬទេ?**

មានការការពារការបណ្តេញចេញ
និងកម្មវិធីហិរញ្ញវត្ថុដែលអាចជួយបាន។

COMMUNITY TEAM WORK



**នេះគឺជាអ្វីដែលអ្នកត្រូវដឹងអំពីការបណ្តេញចេញ និងការរឹបអូសទ្រព្យសម្បត្តិដោយសារបំណុលនៅក្នុងរដ្ឋ Massachusetts៖:**

- ឥឡូវនេះនៅក្នុងរដ្ឋ Massachusetts មានការសងបំណុលទូទាំងរដ្ឋ ឬការផ្អាកការបណ្តេញចេញ និងការរឹបអូសយកទ្រព្យសម្បត្តិជាបណ្តោះអាសន្ន។
- សកម្មភាពនេះបញ្ឈប់ជាបណ្តោះអាសន្ននូវរាល់ការបណ្តេញចេញ និងការរឹបអូសទ្រព្យសម្បត្តិដែលមិនមានលក្ខណៈបន្ទាន់ទាំងអស់សម្រាប់គ្រួសារគ្រប់ប្រភេទរហូតដល់ថ្ងៃទី 17 ខែតុលាឆ្នាំ 2020។
- **អ្នកនៅតែត្រូវបង់ថ្លៃជួល។**

**ប្រសិនបើអ្នកមានការលំបាកក្នុងការធ្វើការបង់ថ្លៃជួល ឬបញ្ចាំ មានធនធានដែលអាចរកបាន៖**

**ចូលទៅកាន់៖ www.commteam.org/covid-erma** ដើម្បីស្វែងយល់បន្ថែមអំពីកម្មវិធីជំនួយហិរញ្ញវត្ថុរបស់រដ្ឋសម្រាប់គ្រួសារដែលមានសិទ្ធិទទួលបាន និងទំនាក់ទំនងទៅនឹងធនធាននានា។

**ហៅទូរសព្ទទៅលេខ៖ 978.459.0551** ដើម្បីទំនាក់ទំនងជាមួយធនធានលំនៅដ្ឋាន។

និយាយជាមួយម្ចាស់ផ្ទះរបស់អ្នកដើម្បីបង្កើតផែនការ - ធ្វើឱ្យទាន់ពេល!

**ប្រសិនបើអ្នកត្រូវការជំនួយក្នុងការបង់ថ្លៃផ្ទះរបស់អ្នក**
**ហៅទូរសព្ទទៅលេខ 978.459.0551**
**ចូលទៅកាន់ WWW.COMMTEAM.ORG/COVID-ERMA**

វាសំខាន់ក្នុងការប្រើការប្រឹងប្រែងរបស់អ្នក ដើម្បីទទួលបានជំនួយលើការជួល ហើយត្រូវបង់ថ្លៃជួលឱ្យបានច្រើនតាមដែលអ្នកអាចធ្វើបានមុនការការពារនៅក្រោមការបញ្ឈប់ការបណ្តេញចេញរបស់រដ្ឋ Massachusetts ផុតកំណត់។



**ក្រុមហ៊ុនអចលនៈទ្រព្យ អឺប៊ឺន រាលអ៊ីស្តេត**

**URBAN REAL ESTATE**

មជ្ឈមណ្ឌលផ្តល់សេវាជួលលំនៅដ្ឋាន

**Residential Leasing Center**



ដាញ៉េល តាន
ភ្នាក់ងារអចលនៈទ្រព្យ

**Daniel Tan**
**Real Estate Agent**
**Cell: 978-902-6354**

**508 Westford Street • Lowell, MA 01851**
**(978) 454-0444**



**ក្រុមហ៊ុនធានារ៉ាប់រងខេខេ អ៊ីនសួរិន អេជេនស៊ី**

**KK Insurance Agency, Inc.**

រថយន្ត • លំនៅដ្ឋាន • អាជីវកម្ម
**Car • Home • Business**

**508 Westford Street**
**Lowell, MA 01851**
**978-970-2212**
**kk@kkinsurancema.com**





## KhmerPost USA, LLC
## សារព័ត៌មានខ្មែរផុសសហរដ្ឋអាមេរិក



**អគ្គនាយក សុបិន្ត ពិន**
Soben Pin, Co-Founder|Publisher
Office: 978 677-7163 | Cell: 978-656-8141
Soben@khmerpostusa.com



**និពន្ធនាយកខ្មែរ** Khmer Editorial
និពន្ធនាយក ពិន សំខុន
Roger Samkhon Pin, Co-founder|Editor
978-942-8490 | pinsamkhon@gmail.com

**ផ្សាយពាណិជ្ជកម្ម សុបិន្ត ពិន**
Advertising Contact
Soben Pin
Cell: 979-656-8141
Soben@khmerpostusa.com

**អ្នកនិពន្ធកិត្តិយស** Staff Writer| Translator
Sokharath Koy | Khmerpostusa@gmail.com

**ច្នៃសោភ័ណ្ឌភាព** Design Artist
Heng Chhun Leng

The KhmerPost USA is a free biweekly Cambodian newspaper and serves the Greater Merrimack Valley, Boston, and Rhode Island. It prints mostly in Khmer and provides important news and information to the people who often are isolated from the larger community due to a language barrier. This includes not only national and international news but practical local information concerning health, education, politics, businesses and community involvement. It publishes twice a month from Lowell, Massachusetts.

Mail subscription is available within the U.S. & Canada at $60.00 year.
Follow us: Facebook | Twitter KhmerpostUSA

# កម្មវិធីជំនួយផ្នែកថែទាំសុខភាពតាមផ្ទះរដ្ឋ

## AccuCare
### Home Care Agency
Group Adults Foster Care Program

***ហើយមិនចង់ចាកចេញពីលំនៅដ្ឋានខ្លួនឯង ឬមិនចង់បែកពីក្រុម គ្រួសារដែលបានរស់នៅជាមួយគ្នាជាយូរមកហើយ ។ សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកតែម្តង ។***

*At no Cost to you*

សេវាថែទាំសុខភាពមួយទល់មួយដល់ផ្ទះលោកអ្នកដោយមិនគិតថ្លៃ អ្នកនឹងត្រូវបានថែទាំដោយក្រុមបុគ្គលិកខ្មែរដែលមានវិជ្ជាជីវៈពី នើស (Nurse), Case Manager និង Home Health Aide បុគ្គលិកមានសណ្តានចិត្តល្អ ទន់ភ្លន់ និងមានការគោរពទំនៀមទំលាប់ខ្មែរ ។ បំរើសេវាក្នុងតំបន់ Lowell, Lynn, Revere, Boston និងតំបន់ជុំវិញ





**ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបានលោកអ្នកត្រូវមានលក្ខណៈដូចខាងក្រោម :**

- *រស់នៅផ្ទះរដ្ឋ*
- *អាយុ ២២ ឆ្នាំឡើងទៅ*
- *មានម៉ាស់ហែលស្តង់ដា*

**ផលប្រយោជន៍ទទួលបាន :**

- *ការថែទាំផ្ទាល់ខ្លួនមួយ ទល់មួយក្នុងផ្ទះរបស់អ្នករាល់ថ្ងៃមួយថ្ងៃមួយម៉ោងលើការរស់នៅប្រចាំថ្ងៃ*
- *ជំនួយលើការគ្រប់គ្រងថ្នាំសង្កូវអ្នក*
- *ផែនការថែទាំសុខភាពផ្ទាល់ខ្លួនមួយ ដែលធ្វើឡើងដោយគ្រូពេទ្យ និងខេសមានីយើ*
- *វាយតំលៃលើសេចក្តីត្រូវការជាប្រចាំជាបន្តបន្ទាប់*
- *សមាជិកអាចទាក់ទងមក២៤ម៉ោង*

**To be eligibled for GAFC you must:**

- *live in subsidized or public housing*
- *age 22 years and older*
- *eligible for Masshealth Standard*

**Benefits you will get:**

- *personal care service in your home,*
- *Medication Managemant*
- *an individual care plan developed by a registered nurse and case manager*
- *ongoing monitoring of needs*
- *24-hour access to services*

## ដើម្បីចុះឈ្មោះសូមទាក់ទងមក
## To register, please contact:

Tel: (978)735-4955, Fax: (978) 735-4956
Office: 144 Merrimack St., Suite 404. Lowell, MA 01852

តមកពីទំព័រទី ០៦

## កម្ពុជា គួរតែបារម្ភជាមួយប្រធានាធិបតី...

ការវិនិយោគអាមេរិកខ្លះនឹងងាកចេញពីប្រទេសកម្ពុជា។

ព្រោះលោកបាយដិននឹងទំនងជាស្វែងរកធ្វើការងារជាមួយសមាគមប្រជាជាតិអាស៊ី អាគ្នេយ៍ នៅលើការជាន់ជើងជាពហុភាគីជាជាងទិន្នាការទ្វេភាគីរបស់ ត្រាំ នោះក៏អាច មានឋានៈស្មើគ្នាជាមួយក្រុងភ្នំពេញ ប្រសិនបើ ប្លុកតំបន់រងសម្ពាធឱ្យកាន់តែមានជំហរមានសម្លេងលើបញ្ហាតំបន់។

"តើរដ្ឋបាលបាយដិន គួរតែទាមទារឱ្យ អាស៊ាន មានជំហរខ្លាំងជាងនេះលើបញ្ហា ដូចជា សិទ្ធិមនុស្ស"? នេះនឹងដាក់រដ្ឋក្នុងតំបន់ក្នុងស្ថាន ភាពមិនងាយស្រួលពាក់ព័ន្ធនឹងផលប្រយោជន៍យុទ្ធសាស្ត្ររៀងៗខ្លួន" យោងតាមអត្ថបទចុះ ផ្សាយនាពេលថ្មីៗ។

តាមពិតកំហឹងតូចមួយបានចាប់ផ្តើមក្នុងខែមុន នៅពេលដែលលោក ប៊ីឡាហារី ខៅសីកាន (Bilahari Kausikan) អតីតរដ្ឋលេខាធិការអចិន្ត្រៃយ៍ក្រសួងការបរទេសសិង្ហបុរីបានស្នើឡើងថា ប្រទេសកម្ពុជា និងឡាវ គួរតែត្រូវបានដេញចេញពីប្លុកអាស៊ាន ព្រោះតែគោលនយោបាយរបស់គេ ត្រូវបានចិនគាបសង្កត់។ គ្មានការសង្ស័យទេ ក្រុងភ្នំពេញទទួលស្គាល់រឿងនេះ ដោយមិន និយាយអ្វីសោះចំពោះអ្នកជិតខាងខ្លួន។

ស្រមៃថា អ្នកការទូតសហគមន៍អ៊ឺរ៉ុប ក៏អាចផ្តើមសួរសមភាគីថ្មីខ្លួន នៅក្នុងរដ្ឋបាល បាយដិន ហេតុអ្វីបានជាអាមេរិកបរាជ័យក្នុងការគាំទ្រខ្លួន នៅពេលដកចេញផ្នែកខ្លះនៃកាអនុគ្រោះពាណិជ្ជកម្មនៅឆ្នាំនេះ។លោកបាយដិនព្យាយាមស្វែង រកការគាំទ្របញ្ចុះបញ្ចូលខាងផ្នែកកសិកម្មឱ្យទទួលយក ប្រសិនបើ សហព័ន្ធស្រូវអង្ករ អាមេរិក ដាក់សម្ពាធម្តងទៀតលើក្រុងវ៉ាស៊ីងតុនឱ្យយក ពន្ធលើការនាំចេញអង្ករកម្ពុជា ដូចដែលខ្លួនបានធ្វើក្នុងខែកក្កដាកន្លងទៅ។

ប្រហែលជារដ្ឋបាល បាយដិន នឹងរក្សាគោលនយោបាយ"ចូលរួម"ជាមួយកម្ពុជាតែជា មួយរូងថ្ម។

អគ្គរដ្ឋទូតប្រចាំក្រុងភ្នំពេញលោក ប៉ាទ្រីក មឺហ្វី (W Patrick Murphy) ដែលលោក ត្រាំ ចាត់តាំងពីឆ្នាំមុននឹងទំនងជានៅបន្តអំឡុងពេលពីរបីឆ្នាំដំបូងនៃរដ្ឋបាល បាយដិន។ ជំនួយ និងការ វិនិយោគនឹងនៅតែផ្តល់ឱ្យដដែល។ រដ្ឋបាល ត្រាំ ត្រូវចេញទៅបានបន្សល់ទុកអ្នកស្នងតំណែងមានច្បាប់ដីមានប្រយោជន៍ ដូចជា ភាព-ជាដៃគូមេគុង -អាមេរិក បានសម្ពោធក្នុងខែកញ្ញា មានទឹកប្រាក់ ចំនួនជាង ១០ពាន់លានដុល្លារ ជាទុននៅពីក្រោយសារជីវកម្មហិរញ្ញប្បទានអភិវឌ្ឍអន្តរជាតិថ្មី ជាមូលនិធិវិនិយោគសាកល។

នៅតែបន្តមូលនិធិសម្រាប់ការអភិវឌ្ឍក្នុង មូលដ្ឋាននៅកម្ពុជា និងវិស័យឯកជនរបស់ខ្លួនអាចភ្ជាប់ជាមួយសម្ពាធកាន់តែច្រើន ជាការពិត ដើម្បីធ្វើឱ្យរីកចម្រើនខាងលទ្ធិប្រជាធិបតេយ្យ និងសិទ្ធមនុស្សព្រោះតែស្ថានភាពទាំងពីរ បានរអិលចុះពីលើកំពូលភ្នំចាប់តាំងពីឆ្នាំមុន។

ជាសង្ខេប រដ្ឋបាល បាយដិន អាចទទួល ទាំងការ៉ុត និងដំបងសម្រាប់កម្ពុជា។ ប៉ុន្តែក្រុង ភ្នំពេញនៅតែទទួលស្គាល់ថាខ្លួនអាចបន្តជា ធម្មតាកំពុងជឿថា អាមេរិកសប្បាយចិត្តរក្សា ទុកក្នុងដៃជៀសវាង "ការបាត់បង់" កម្ពុជាទៅ ចិន វាអាចជា-កំហុសឆ្គងមួយមានតម្លៃស្រដៀងគ្នា ទៅនឹងរឿងមួយដែល ហ៊ុន សែន បានធ្វើនៅពេលគាត់សន្មត់ថា សហគមន៍អ៊ឺរ៉ុបនឹងមិនកាត់ការអនុគ្រោះពាណិជ្ជកម្មកម្ពុជា។

លោក ដេវីដ ហាត់ គឺជាអ្នកកាសែតនយោបាយមានមូលដ្ឋាន នៅសាធារណៈឆែក និង អង់គ្លេស។ ចន្លោះ ឆ្នាំ ២០១៤ ដល់២០១៩ គាត់បាននៅប្រទេសកម្ពុជាផ្តោតលើកិច្ចការអាស៊ីអគ្នេយ៍។ គាត់គឺជាស្មេរអាស៊ីអគ្នេយ៍ឱ្យកាសែត ឌឹ ឌីផ្លូមមាត (The Diplomat) និងជា អ្នកចូលរួមចំណែក កាសែតអាស៊ីថែម (Asia Times) និងការសរសេរគំនិតសេរី (column Free Thoughts)។គាត់រាយការណ៍អំពីកិច្ចការ នយោបាយអ៊ឺរ៉ុប និងទំនាក់ទំនងអ៊ឺរ៉ុប-អាស៊ាន។ ជួបគាត់តាម Twitter @davidhuttjourno។




Continued from page 12

## A Cambodian American Civil Rights Lawyer Theary C. Seng and 67 others Face Trials for Treason in Cambodia on Thanksgiving Day

happens, it never has a good ending for any country".

In an interview with Khmer Post USA, Jared said "I will spare no efforts if Theary is detained to make sure her story is known by people around the world. What she is going through. Make sure we go after him and his cronies through target sanctions, assets freeze, to make him and his regime accountable, obviously ultimately to secure Theary's release, and to highlight the broader human rights situation in Cambodia with the goal to force him to relent and step back from the oppression".

"Talking about treason. He [Prime Minister Hun Sen] should be charged with treason, because treason is to sell the soul of a nation for foreigners" Theary said.

In October, Cambodia King Norodom Sihamoni spent an extensive amount of time in China after Prime Minister Hun Sen introduced his son, Hun Manet, a current top general of Cambodia military, to Chinese president Xi. As has been shown in recent months, Prime Minister Hun Sen chose to look to China and ignored the United States and the European Union. It should be noted that Cambodia owes more $500 million in U.S. loans under the 1970-75 Lon Nol government, and $1.5 billion of debt to Russia during the Vietnamese 1979-89 occupation. In contrast China has forgiven debts incurred during the Khmer Rouge era 1975-79. More recently, China has a footing in Cambodia building an airport and businesses. While Cambodia policies has aligned with China on the surface and overlooked by the international community, Prime Minister Hun Sen is working on fulfilling the 2005 treaty with Vietnam, in he which ignored and violated the international 1991 Paris Peace Agreement Accords on Cambodia. In recent months, Vietnam border posts were reportedly moved into Cambodia land and the villagers reported their lost of lands. Mr. Rong Chhun and his supporters were arrested and jailed for speaking up about the border issue with Vietnam.

ការិយាល័យ មេធាវី
ថំមាស ស្តាលីយ៉ាណូស

Law Office of Thomas Stylianos Jr.
287 Appleton St. Lowell MA 01852

- Immigration •អន្តោប្រវេសន៍
- Auto Crash •គ្រោះថ្នាក់រថយន្ត
- Divorce •លែងលះប្តីប្រពន្ធ

សូមទាក់ទង សោភា ឬ ធំ 978-459-5000 or 800-308-3766
www.thomasinlowell.com


KhmerPost USA
FREE BIWEEKLY CAMBODIAN ENGLISH NEWSPAPER SINCE 2007
The Only Khmer/English Newspaper Serving the Cambodian Community of New England
Lowell
Lynn
Revere
Providence
Cranston
CELEBRATING 10 YEARS
PUBLISHING
Two Issues Every Month
READERSHIP
50,000 Monthly
600,000 Annually
FOLLOW US
KhmerPostUSA
@KhmerPostUSA
Khmer Post USA Distribution Locations Include:
• Households
• Markets
• Retail Businesses
• Restaurants
• Office Buildings
• Government Offices
• Chamber of Commerce
• Buddhist Temples
• Laundromats
• And Much More
www.khmerpostusa.com
P.O. Box 8848 Lowell, MA 01853
Direct: 978-656-8141 • Email: soben@khmerpostusa.com